រាជរដ្ឋាភិបាលកម្ពុជា

ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

# កម្រងព័ត៌មាន
# សេវាសាធារណៈ

## ចង្កោមសេវាទី២ ទី៥
## ទី៦ និងទី៧

ខែមករា ឆ្នាំ២០១១



សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

និងជាប្រធានឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ

# បុព្វកថា

ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ គឺជាគោលដៅអាទិភាពមួយដ៏សំខាន់នៅក្នុងកម្មវិធីកំណែទម្រង់រដ្ឋបាលដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា។

ការផ្តល់សេវាសាធារណៈ ប្រកបដោយគុណភាពគឺជាការងារដ៏មានសារៈសំខាន់ និងមានលក្ខណៈយុទ្ធសាស្ត្រមិនអាចធ្វេសប្រហែស ឬមើលរំលងបាន ហើយត្រូវតែផ្តោតការយកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តទូទាំងប្រទេស ស្របទៅតាមទីកន្លែង និងពេលវេលា តម្រូវការរបស់ប្រជាពលរដ្ឋ ក្នុងទិសដៅឈានទៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងការកាត់បន្ថយភាពក្រីក្រ។ សន្តិភាព ស្ថិរភាព សន្តិសុខ ជាសមិទ្ធផលដ៏សំខាន់ដែលរាជរដ្ឋាភិបាលសម្រេចបាន ហើយក៏ជាមូលដ្ឋានគ្រឹះសម្រាប់ពង្រឹងទំនុកចិត្តរបស់ប្រជាពលរដ្ឋមកលើរាជរដ្ឋាភិបាល ដែលជាលក្ខខណ្ឌដ៏ចាំបាច់ក្នុងការអភិវឌ្ឍប្រកបដោយចីរភាព យុត្តិធម៌សង្គម និងកាត់បន្ថយភាពក្រីក្រ។ សមិទ្ធផលទាំងនេះ ត្រូវបន្តបំពេញបន្ថែមដោយការពង្រឹងគុណភាពនៃសេវាសាធារណៈដែលប្រជាពលរដ្ឋត្រូវការ។

រាជរដ្ឋាភិបាលបានអនុម័តគោលនយោបាយស្តីពី ការផ្តល់សេវាសាធារណៈ នាថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦ សម្រាប់ជាគោលការណ៍រួមក្នុងការកែលម្អការផ្តល់សេវាជូនប្រជាពលរដ្ឋ។ គោលនយោបាយដ៏សំខាន់នេះ ត្រូវបានបោះពុម្ពជាកូនសៀវភៅ និងបានចែកផ្សព្វផ្សាយយ៉ាងទូលំទូលាយ។ ការអនុវត្តគោលនយោបាយនេះ តម្រូវឱ្យមន្ត្រីរាជការផ្លាស់ប្តូរឥរិយាបថ និងរបៀបក្នុងការផ្តល់សេវាសាធារណៈ។ ក្នុងន័យនេះ រដ្ឋបាលសាធារណៈត្រូវធ្វើការកែទម្រង់ស៊ីជម្រៅ ប្រែក្លាយខ្លួនទៅជាអ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាព និងជាដៃគូអភិវឌ្ឍន៍ ដែលអាចជឿទុកចិត្តបាន។

ដូចបានបញ្ជាក់នៅក្នុងគោលនយោបាយស្តីពី ការផ្តល់សេវាសាធារណៈរួចហើយថា គុណសម្បត្តិនៃឥរិយាបថមន្ត្រីរាជការត្រូវមានលក្ខណសម្បត្តិស្នូលសំខាន់ៗបួនដូចខាងក្រោម ដើម្បីបម្រើប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរឡើង :

**១. ឆន្ទៈម្ចាស់ការ** ខិតខំបំពេញកិច្ចការដែលត្រូវធ្វើអស់ពីលទ្ធភាព

**២. ភក្តីភាព** ចំពោះប្រជាពលរដ្ឋ និងចំពោះស្ថាប័នរដ្ឋ

**៣. មនសិការវិជ្ជាជីវៈ** ដើម្បីធានានូវសមត្ថភាពបំពេញការងារប្រកបដោយប្រសិទ្ធភាព និង គណនេយ្យភាព

**៤. វប្បធម៌សេវាសាធារណៈ** ដោយត្រូវឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ និងកែប្រែរបៀបរបបនៃការបំពេញការងារ ក្នុងគោលបំណងបម្រើប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរឡើង។

កម្រងព័ត៌មានសេវាសាធារណៈនេះ ត្រូវផ្សព្វផ្សាយយ៉ាងទូលំទូលាយព្រោះនេះ គឺជាជំហានដ៏សំខាន់សម្រាប់ផ្តល់នូវព័ត៌មានចាំបាច់ ពាក់ព័ន្ធទៅនឹងសេវាសាធារណៈនីមួយៗដែលត្រូវផ្តល់ដោយរដ្ឋបាលសាធារណៈ។ កម្រងព័ត៌មានសេវាសាធារណៈនេះក៏បញ្ជាក់ផងដែរអំពីវិសាលភាពនៃការងាររបស់រដ្ឋបាលសាធារណៈ ចាប់តាំងពីសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពនៃរដ្ឋ សេវាសុខភាព សេវាអប់រំ សេវាសម្រាប់សហគ្រិននានា រហូតដល់សេវាសាងសង់ និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធ។

កម្រងព័ត៌មានសេវាសាធារណៈ ជាឧបករណ៍ចាំបាច់សម្រាប់ពង្រឹងតម្លាភាព និងគណនេយ្យភាព។ ជាជំហានបន្តបន្ទាប់ ក្រសួង ស្ថាប័នទាំងអស់ត្រូវពិនិត្យមើលឡើងវិញនូវការផ្តល់សេវានីមួយៗរបស់ខ្លួនឱ្យកាន់តែឆ្លើយតបបានទៅនឹងតម្រូវការ មានប្រសិទ្ធភាព និងតម្លាភាព។ ជាមួយនេះ ក៏ត្រូវធ្វើឱ្យការទទួលសេវាទាំងអស់នោះ មានភាពងាយស្រួល ភាពរាក់ទាក់ ទាន់ពេលវេលា។

បម្រើប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរឡើង គឺដើម្បីសុខុមាលភាពរបស់ប្រជាពលរដ្ឋ និងវិបុលភាពប្រទេសជាតិយើង។

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩



**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**
**និងជាប្រធានឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ**



ឯកឧត្តម  សុខ  អាន

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

អនុប្រធានអចិន្ត្រៃយ៍ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ

និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

# អារម្ភកថា

គោលដៅ នៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាល គឺត្រូវធ្វើឱ្យទំនើបនូវរដ្ឋបាលសាធារណៈ ដើម្បីបម្រើប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរឡើង ដោយប្រែក្លាយរដ្ឋបាលនេះឱ្យទៅជា អ្នកផ្តល់សេវាសាធារណៈដ៏មានប្រសិទ្ធភាព និងជាដៃគូអភិវឌ្ឍន៍ដែលអាចជឿទុកចិត្តបាន។ ដើម្បីសម្រេចនូវគោលដៅនេះរាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រដែលមានលក្ខណៈទូលំទូលាយ ងាយយល់ និងស៊ីជម្រៅ រួមជាមួយនឹងសកម្មភាពដែលបានកំណត់យ៉ាងច្បាស់ តាមរយៈការធ្វើឱ្យរដ្ឋបាលសាធារណៈកាន់តែមានតម្លាភាព ភាពឆ្លើយតប និងប្រសិទ្ធភាព និងតាមរយៈការលើកកម្ពស់ឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ។

គោលនយោបាយស្តីពី ការផ្តល់សេវាសាធារណៈ គឺជាស្នូលនៃការធ្វើកំណែទម្រង់រដ្ឋបាល។ គោលនយោបាយនេះផ្តល់ឱ្យបណ្តាក្រសួង ស្ថាប័ននូវវិធីសាស្ត្រ និងយន្តការនានា ដើម្បីកែលម្អគុណភាព និងផ្តល់សេវារបស់ក្រសួង ស្ថាប័នជូនប្រជាជនតាមតម្រូវការ នៅតាមទីកន្លែង និងទាន់ពេលវេលា ក្នុងគោលដៅធ្វើឱ្យសេវាសាធារណៈទាំងនោះអាចជឿទុកចិត្តបាន ងាយស្រួលនឹងទទួលបាន ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង និងមានតម្លាភាព។ នេះគឺមានន័យថា អ្នកប្រើប្រាស់សេវាទាំងអស់នឹងត្រូវទទួលបានដោយងាយស្រួលនូវសេវាសាធារណៈដែលគួរឱ្យជឿទុកចិត្ត មានប្រសិទ្ធភាព និងមានព័ត៌មានពេញលេញទាក់ទងនឹងការផ្តល់សេវា។

សេវាសាធារណៈដែលក្រសួង ស្ថាប័នកំពុងផ្តល់ជូនប្រជាពលរដ្ឋ ត្រូវបានប្រមូលផ្តុំជា ០៧ ចង្កោមប្រភេទសេវា។ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល បានសហការយ៉ាងជិតស្និទ្ធជាមួយបណ្តាក្រសួង ស្ថាប័នសាមី ក្នុងការរៀបចំចងក្រង និងបោះពុម្ពជាកូនសៀវភៅកម្រងព័ត៌មានសេវាសាធារណៈតាមចង្កោមសេវានីមួយៗ ដោយផ្តោតការយកចិត្តទុកដាក់ជាអាទិភាពលើព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងការផ្តល់សេវានីមួយៗ។

កម្រងព័ត៌មានសេវាសាធារណៈនេះ ចងក្រងព័ត៌មានទៅតាមក្រសួង ស្ថាប័ន ហើយនៅក្នុងសេវានីមួយៗ ក៏ត្រូវបានបញ្ជាក់យ៉ាងជាក់លាក់នូវក្រសួង ស្ថាប័នផ្តល់សេវា គោលបំណងនៃការផ្តល់សេវាមូលដ្ឋានគតិយុត្ត អ្នកដែលមានសិទ្ធិទទួលសេវា ស្តង់ដាសេវា តម្រូវការឯកសារដើម្បីទទួលបានសេវា និងថ្លៃសេវាដែលត្រូវបង់។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណ និងលើកទឹកចិត្តចំពោះការចូលរួមចំណែក និងកិច្ចខិតខំប្រឹងប្រែងរបស់បណ្តាក្រសួង ស្ថាប័នដែលបានសហការយ៉ាងជិតស្និទ្ធដល់ការចងក្រងកម្រងព័ត៌មានសេវា

សាធារណៈ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្រសួង ស្ថាប័នទាំងអស់ នឹងបន្តខិតខំអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ថែមទៀតនូវការផ្តល់សេវារបស់ខ្លួនទៅតាមព័ត៌មាន ដែលមានចែងនៅក្នុងកូនសៀវភៅកម្រងព័ត៌មានសេវាសាធារណៈនេះ និងបន្តកែលម្អជាបន្តបន្ទាប់ ដើម្បីបន្តការពេញចិត្តពេញថ្លើមរបស់អ្នកប្រើប្រាស់សេវា។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩



**សុខ អាន**

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**អនុប្រធានអចិន្ត្រៃយ៍ ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ**

**និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

# បម្រើប្រជាជនឱ្យបានកាន់តែល្អប្រសើរឡើង
# គឺដើម្បីសុខុមាលភាពរបស់ប្រជាពលរដ្ឋ
# និងវិបុលភាពប្រទេសជាតិយើង

# មាតិកា

- **បុព្វកថា**........................................ii
- **អារម្ភកថា**........................................v
- **មាតិកា**........................................viii
- **កម្រងព័ត៌មានសេវាសាធារណៈ**........................................១
  - ១-សេចក្តីផ្តើម........................................១
  - ២- គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ........................................២
- **ការប្រើប្រាស់កម្រងព័ត៌មានសេវាសាធារណៈ**........................................៥
  - ១- អត្ថន័យកម្រងព័ត៌មានសេវាសាធារណៈ........................................៥
  - ២- កម្មវត្ថុនៃកម្រងព័ត៌មានសេវាសាធារណៈ........................................៥
  - ៣- រចនាសម្ព័ន្ធនៃកម្រងព័ត៌មានសេវាសាធារណៈ........................................៥
  - ៤- ការទទួលខុសត្រូវក្នុងការធ្វើបច្ចុប្បន្នភាពព័ត៌មាន........................................៩
  - ៥- តើមានឯកសារអ្វីខ្លះដែលអាចរកមើលបាន?........................................៩

**ក្រសួងការពារជាតិ**

- ទំព័រព័ត៌មានសេវាអប់រំបន្សាបសារធាតុគ្រឿងញៀន ........................................១២
- ទំព័រព័ត៌មានរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម........................................១៣

**ក្រសួងអភិវឌ្ឍន៍ជនបទ**

- គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទនៅខេត្តកំពង់ចាម( ការផ្តល់សេវាឥណទាន ជនបទ)........១៩
- សាងសង់ប្រើប្រាសបង្គន់អនាម័យ និងការប្រតិបត្តិអនាម័យល្អ........................................២១
- ផ្តល់វិញ្ញាបនបត្របច្ចេកទេសខួងអណ្តូង........................................២៣
- ការសាងសង់ និងជុសជុលអណ្តូងគ្រប់ប្រភេទ........................................២៤
- ការវិភាគគុណភាពទឹក........................................២៥
- សាងសង់ ស្ពារ និងជុសជុលប្រព័ន្ធធារាសាស្ត្រខ្នាតតូច ........................................២៦

- ផ្តល់មុខជំនាញវិជ្ជាជីវៈដល់ប្រជាពលរដ្ឋ នៅជនបទ ........ ២៧
- សេវាសាងសង់ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ជនបទ ........ ២៩

## ក្រសួង កិច្ចការនារី

- កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី ........ ៣១
- ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ........ ៣៣

## ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- របបឧបត្ថម្ភគោលនយោបាយចំពោះជនពិការស្នាក់នៅក្នុងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទារបស់រដ្ឋ ........ ៣៥
- របបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ ........ ៣៧
- ការផ្តល់របបសន្តិសុខសង្គមជូនមន្ត្រីរាជការស៊ីវិល និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក ........ ៣៩
- កម្មវិធីជំនួយសង្គ្រោះប្រជាជនរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតុ ........ ៤៥
- កម្មវិធីការពារជនផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ........ ៤៨
- ការបើកផ្តល់របបសន្តិសុខសង្គម ជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន ........ ៥០
- កិច្ចសហប្រតិបត្តិការ លើវិស័យអធិការកិច្ចការថែទាំជំនួសចំពោះកុមារ ........ ៥៧
- កិច្ចសហប្រតិបត្តិការលើវិស័យសុំកូនអន្តរប្រទេស ........ ៥៩
- ការផ្តល់សេវាជួយដល់អតីតយុទ្ធជននិងគ្រួសារក្រីក្រនៅតាមសហគមន៍ ........ ៦១
- ការបង្កើតមជ្ឈមណ្ឌល និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ ........ ៦៣
- របបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ ........ ៦៨
- ការដោះស្រាយបញ្ហាជនអនាថា ........ ៧០
- កម្មវិធីស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ........ ៧៣

## ក្រសួងអប់រំ យុវជន និងកីឡា

- ផ្តល់ការអប់រំសម្រាប់ទាំងអស់គ្នា ........ ៧៧

## ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


- ផ្តល់លិខិតប្រកាសឥណទានពីការកាត់ពន្ធអាករលើរបបម៉ៅការ និង របបពិត ........................... ៨០
- ផ្តល់លិខិតប្រកាសឥណទានពីការកាត់ពន្ធ លើប្រាក់បៀវត្ស ........................... ៨១
- ផ្តល់ប័ណ្ណបង់ប្រាក់នៅអគ្គនាយកដ្ឋានរតនាគាជាតិ ........................... ៨២
- ផ្តល់សលាកប័ត្របង្វែរចំណូលចូលថវិកា ........................... ៨៣
- ការទទួលបានប្រកាសឥណទានពីធានាគារស្តីពីចំណូលមិនមែនសារពើពន្ធ ........................... ៨៤
- ការទទួលបានប្រកាសឥណទានពីធនាគារស្តីពីចំណូលពន្ធដា និងពន្ធគយ ........................... ៨៥
- ការប្រកាសចំណូលពន្ធដាមកពីរាជធានី-ខេត្ត ........................... ៨៦
- ការប្រកាសវេជ្ជទេយ្យចំណូលមកពីរាជធានី-ខេត្ត ........................... ៨៧

**អាសយដ្ឋាន និងគេហទំព័រសំខាន់ៗ** ........................... ៨៨

# កម្រងព័ត៌មានសេវាសាធារណៈ

## ១-សេចក្តីផ្តើម

ទោះបីរដ្ឋបាលសាធារណៈ បានឆ្លងកាត់នូវការផ្លាស់ប្តូរ និងការធ្វើកំណែទម្រង់ជាបន្តបន្ទាប់យ៉ាងណាក៏ដោយ ក៏មិនទាន់ឆ្លើយតបបានទាំងស្រុងនៅឡើយទៅនឹងតម្រូវការរបស់ប្រទេសជាតិ ដែលកាន់តែមានទំហំធំឡើងៗ នៅក្នុងបរិបទនៃសកលភាវូបនីយកម្ម។ ក្នុងន័យនេះ មិនមែនតែប្រទេសកម្ពុជាទេ គឺមានប្រទេសជាច្រើនបាន ធ្វើការផ្លាស់ប្តូរប្រព័ន្ធផ្តល់សេវាមកតាមរបៀបជាទំនាក់ទំនងរវាងអ្នកត្រួតត្រាគេ និងអ្នកដែលត្រូវគេត្រួតត្រា ទៅជាទំនាក់ទំនងថ្មី គឺជាទំនាក់ទំនងរវាងអ្នកផ្តល់សេវា និងអ្នកប្រើប្រាស់សេវាទៅវិញ ពោលគឺ ប្រជាពលរដ្ឋ មិនត្រូវរត់សំណុំឯកសាររបស់ខ្លួនទៅរាប់សិបអង្គភាពរដ្ឋបាល និងចំណាយពេល និងប្រាក់យ៉ាងច្រើនដើម្បីទទួល បានការអនុញ្ញាតដូចមុនទៀតទេ ព្រោះថាការបញ្ជូនឯកសារចុះឡើងរបៀបនោះជាកិច្ចការរបស់រដ្ឋ ដែលរដ្ឋត្រូវ រ៉ាប់រងធ្វើមិនត្រូវឱ្យប្រជាពលរដ្ឋធ្វើជំនួសឡើយ។

ការរីកចំរើនខាងវិស័យឯកជន ក៏ជាស្ថានភាពមួយដែលតម្រូវឱ្យរដ្ឋត្រូវពង្រឹងស្ថាប័ន និងតួនាទីរបស់ខ្លួន ដើម្បីកែលម្អការផ្តល់សេវាសាធារណៈជូនផ្នែកឯកជន ដែលជាដៃគូរបស់ខ្លួនក្នុងកិច្ចអភិវឌ្ឍប្រទេសជាតិ។ ការ កែលម្អសេវាសាធារណៈ មានន័យថាជាវិធានការជាក់ស្តែងមួយនៅក្នុងក្របខ័ណ្ឌកំណែទម្រង់ ដើម្បីនាំទៅដល់ គោលដៅ ឬស្ថានភាពមួយដែលប្រជាពលរដ្ឋអាចទទួលបានសេវាសាធារណៈទាន់ពេលវេលា មានតម្លាភាព មាន ប្រសិទ្ធភាព តាមតម្លៃសមរម្យ និងឆ្លើយតបទៅនឹងតម្រូវការ តាមរយៈការកែលម្អនីតិវិធីផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋតាមរបៀបសាមញ្ញ មានគុណភាព និងចំណាយអស់តិច ហើយអាចសម្រួលឱ្យប្រជាពលរដ្ឋទទួល បានសេវាសាធារណៈទាន់ពេលវេលា។

ការកែលម្អសេវាសាធារណៈ ត្រូវធ្វើឡើងទៅតាមសភាពការណ៍ជាក់ស្តែង និងជាជំហានៗ ដើម្បីប្រែក្លាយ សេវាសាធារណៈឱ្យមាន **គុណភាពល្អ តម្លៃថោក ខ្លី សាមញ្ញ អាចជឿទុកចិត្តបាន ឆ្លើយតបទាន់ពេលវេលា ទៅនឹងតម្រូវការ និងបង្កលក្ខណៈងាយស្រួល**ដល់អ្នកប្រើប្រាស់សេវា។

ផ្លូវទៅមុខ គឺវែងឆ្ងាយណាស់ ប៉ុន្តែយើងមានតម្រូវការជាបន្ទាន់ច្រើន ហើយមធ្យោបាយដើម្បីប្រើប្រាស់ នៅមានកម្រិត។ ដូច្នេះការកំណត់អាទិភាព និងការធ្វើចំណាត់ថ្នាក់សកម្មភាព គឺត្រូវធ្វើក្នុងស្មារតីប្រុងប្រយ័ត្ន ខ្ពស់ជាទីបំផុត។ ការផ្តល់សេវា គឺមិនត្រឹមតែត្រូវធ្វើដើម្បីកាត់បន្ថយភាពក្រិក្រប៉ុណ្ណោះទេ ប៉ុន្តែជាយន្តការក្នុង ការកែលម្អឱ្យមានភាពល្អប្រសើរជាងមុនដល់ស្ថាប័នខ្លួនផងដែរ។ រដ្ឋបាលមិនត្រឹមតែត្រូវនៅជិតប្រជាពលរដ្ឋ ប៉ុណ្ណោះទេ ប៉ុន្តែត្រូវប្រឹងប្រែងឱ្យអស់ពីលទ្ធភាព ដើម្បីផ្តល់សេវាជូនប្រជាពលរដ្ឋឱ្យបានឆាប់រហ័សមាន គុណភាព

ល្អ និងមានតម្លាភាព។ ការពង្រឹងសេវាសាធារណៈនឹងអាចធ្វើឱ្យផ្លាស់ប្តូរបាននូវអាកប្បកិរិយា និងឥរិយាបទរបស់មន្ត្រីរាជការ និងអ្នកប្រើប្រាស់សេវាសាធារណៈ ។

## ២-គោលនយោបាយស្តីពី ការផ្តល់សេវាសាធារណៈ

គោលដៅនៃការកែលម្អការផ្តល់សេវា គឺធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃការផ្តល់សេវាសាធារណៈទៅតាមប្រភេទសេវានីមួយៗ ដោយប្រើប្រាស់បរិធានចំរុះដែលគិតចាប់ពីការធ្វើឯកជនរូបនីយកម្ម និងការធ្វើកិច្ចសន្យាក្រៅ រហូតដល់ការធ្វើវិមជ្ឈការ និងវិសហមជ្ឈការ និងការប្រើប្រាស់នូវរបៀបផ្តល់សេវាផ្សេងៗទៀត ជាពិសេសការរៀបចំបង្កើត និងដំណើរប្រព្រឹត្តទៅនៃទីភ្នាក់ងារប្រតិបត្តិការពិសេស(SOA)។ រាជរដ្ឋាភិបាលបានរៀបចំគោលនយោបាយស្តីពី ការផ្តល់សេវាសាធារណៈ ដែលជាលទ្ធផលនៃការចូលរួមពិភាក្សា និងការផ្លាស់ប្តូរយោបល់ជាច្រើនលើកច្រើនសារពីគ្រប់ក្រសួង ស្ថាប័ន តាមរយៈកិច្ចប្រជុំអន្តរក្រសួង រហូតទទួលបានការអនុម័តពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦។

ដើម្បីធ្វើឱ្យគោលនយោបាយស្តីពី ការផ្តល់សេវាសាធារណៈនេះអនុវត្តទៅបានប្រកបដោយជោគជ័យ រាជរដ្ឋាភិបាលប្រគល់ដល់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលនូវភារកិច្ច និងតួនាទីក្នុងការផ្តួចផ្តើមគំនិត សម្របសម្រួល ជំរុញ និងឃ្លាំមើលការអនុវត្តទាំងផ្នែកបច្ចេកទេស និងបទពិសោធន៍ ហើយរួមសហការគ្នាយ៉ាងជិតស្និទ្ធ ជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរខេត្ត ក្រុង។

ជាងនេះទៅទៀត គ្រប់ក្រសួង ស្ថាប័ន និងអាជ្ញាធររាជធានី ខេត្ត គឺជាអ្នកទទួលខុសត្រូវចំពោះគុណភាព និងការផ្តល់សេវាសាធារណៈដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ហើយរដ្ឋមន្ត្រីគឺជាអ្នកដឹកនាំធ្វើកំណែទម្រង់ក្នុងផ្នែករបស់ខ្លួននៅក្នុងក្រសួង ស្ថាប័ន។ ហេតុនេះ ការអនុវត្តគោលនយោបាយស្តីពី ការផ្តល់សេវាសាធារណៈនេះ ទាមទារឱ្យមានការចូលរួមយ៉ាងសកម្មពីគ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធ សង្គមស៊ីវិល ព្រមទាំងភាគីពាក់ព័ន្ធទាំងអស់ក៏ដូចជាដៃគូអភិវឌ្ឍន៍ នានារបស់កម្ពុជា សំដៅបម្រើប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរឡើងនូវគុណភាព ប្រសិទ្ធភាព និងការទទួលខុសត្រូវ។

ម្យ៉ាងទៀត ជោគជ័យនៃការងារកំណែទម្រង់នេះ ក៏អាស្រ័យទៅលើល្បឿននៃការផ្លាស់ប្តូរផ្នត់គំនិត និងទម្លាប់ការងាររបស់មន្ត្រីរាជការពីអ្នកត្រួតត្រាគេ ទៅជាអ្នកផ្តល់សេវា ។ ការផ្លាស់ប្តូរប្រកបដោយនិរន្តរភាព និងពង្រឹងភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់របស់កម្ពុជា។

យើងអាចចែករំលែកនូវទស្សនទាន និងចក្ខុវិស័យមួយចំនួនស្តីពីការធ្វើទំនើបកម្មវិស័យសាធារណៈដែលពាក់ព័ន្ធយើងទាំងអស់គ្នា និងដែលប្រទេសកម្ពុជាកំពុងតែតម្រង់ទិសទៅរក ដើម្បីធានានូវការរីកចំរើនប្រកបដោយចិរភាព និងមានតួនាទីកាន់តែសំខាន់ឡើងនៅតំបន់ និងលើឆាកអន្តរជាតិ។

១- បទពិសោធន៍នៃការធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈនៅក្នុងអំឡុងពេលប៉ុន្មានទសវត្សចុងក្រោយនេះ បង្ហាញឱ្យឃើញថាជោគជ័យនៃកំណែទម្រង់ គឺអាស្រ័យលើកត្តាមួយចំនួនដូចជា ៖

- ការផ្លាស់ប្តូរឥរិយាបថ វប្បធម៌ និងរបៀបធ្វើការងាររបស់ភ្នាក់ងារសាធារណៈ (មន្ត្រីរាជការ) និងស្ថាប័ន។
- កិច្ចប្រឹងប្រែងធ្វើទំនើបកម្ម ត្រូវតែស្របទៅនឹងបរិបទ តម្រូវការ និងកាលៈទេសៈរបស់ប្រទេស។
- រដ្ឋ ត្រូវយល់ច្បាស់ពីភាពសកម្មប្រកបដោយថាមពលរបស់ប្រព័ន្ធរដ្ឋបាលសាធារណៈផ្ទាល់របស់ខ្លួនមុននឹងបង្កើតយុទ្ធសាស្ត្រកំណែទម្រង់ត្រឹមត្រូវមួយ។ អាជ្ញាធរសាធារណៈ ត្រូវចងចាំផងដែរថា អភិបាលកិច្ចសាធារណៈ និងរដ្ឋបាលសាធារណៈមិនអាចកាត់ផ្តាច់ចេញពីគ្នាបាននោះទេ។
- ការធ្វើកំណែទម្រង់ ឬទំនើបកម្ម គឺជាអភិក្រមបន្តជាយូរអង្វែង ពីព្រោះថា ខណៈដែលសង្គមវិវត្តទៅមុខឥតឈប់ឈរ នោះរដ្ឋបាលសាធារណៈ ត្រូវតែសម្របទៅតាមការវិវត្តនេះជាអចិន្ត្រៃយ៍។

២- នៅក្នុងចំណោមការផ្លាស់ប្តូរនៅក្នុងផ្នែកសាធារណៈ ដែលរាជរដ្ឋាភិបាលយើងចង់សម្រេចបាន នាពេលអនាគតតាមលទ្ធភាពដែលអាចធ្វើទៅបាន ដូចដែលប្រទេសជឿនលឿនជាច្រើនកំពុងតែអនុវត្តនោះ រួមមាន ៖

- រដ្ឋបាលបើកចំហ គឺជារដ្ឋបាលមួយដែលផ្សព្វផ្សាយព័ត៌មានដែលប្រជាពលរដ្ឋចង់បាន ជាពិសេសតាមរយៈបច្ចេកវិជ្ជាព័ត៌មានវិទ្យា និងដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋយល់កាន់តែច្រើនឡើងពីអង្គភាពនានារបស់រដ្ឋ និងចូលរួមនៅក្នុងអភិក្រមនៃការធ្វើសេចក្តីសម្រេចចិត្ត។ នេះគឺជាការផ្លាស់ប្តូរវប្បធម៌មួយយ៉ាងសំខាន់។ ដូចនេះ រដ្ឋបាលបើកចំហអាចពង្រឹងភាពពេញច្បាប់ និងជំនឿទុកចិត្តមកលើរាជរដ្ឋាភិបាល និងជួយរដ្ឋាភិបាលឱ្យឆ្លើយតបនឹងតម្រូវការខាងសេវាកម្ម និងព័ត៌មានងាយស្រួលទទួលបាន និងប្រកបដោយគុណភាពពីសំណាក់ប្រជាពលរដ្ឋ។
- តម្រូវការខាងផ្លាស់ប្តូររចនាសម្ព័ន្ធគ្រប់គ្រង និងការងារ គឺសំដៅទៅលើការកែសម្រួលរចនាសម្ព័ន្ធរដ្ឋបាល និងគ្រប់គ្រងការងារ និងការផ្តល់ធនធានមនុស្ស និងហិរញ្ញវត្ថុ ដែលអាចធានាបាននូវប្រសិទ្ធភាពខ្ពស់។ ចំពោះអង្គការនីតិប្រតិបត្តិទំនើបមួយ ប្រការដែលមានលទ្ធភាពកែសម្រួលទម្រង់រៀបចំនៃផ្នែកសាធារណៈនៅក្នុងកាលានុវត្តភាពអនុគ្រោះ គឺពិតជាមានសារៈសំខាន់ណាស់។ យោងតាមការរីកចំរើននៃគណនេយ្យ និងបច្ចេកវិជ្ជាព័ត៌មាន ការផ្តល់ស្វ័យភាពគ្រប់គ្រងដល់ទីភ្នាក់ងារសាធារណៈ (គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ អាជ្ញាធរនិយ័តកម្ម...។ល។) មានភាពងាយស្រួលជាងមុន ហើយនិងអនុញ្ញាតឱ្យមានទីភ្នាក់ងាររដ្ឋជាច្រើន ដែលមានការទទួលខុសត្រូវតាមជំនាញពិសេសៗ។ ការបង្កើតរចនាសម្ព័ន្ធរដ្ឋបាលបែបថ្មីទំនើបនេះ និងការធ្វើវិមជ្ឈការ និងវិសហមជ្ឈការ នៃការគ្រប់គ្រង និងការផ្តល់សេវាប្រភេទទីផ្សារ នឹងបង្កើនលទ្ធផល និង ប្រសិទ្ធភាព។

- យន្តការប្រភេទទីផ្សារ ត្រូវបានប្រើប្រាស់កាន់តែច្រើនឡើងនៅក្នុងផ្នែកសាធារណៈ។ អាជ្ញាធរសាធារណៈបានចាត់វិធានការបង្កើនប្រសិទ្ធភាពផ្នែកសាធារណៈ ដូចជាការប្រគល់សេវាកម្មមួយចំនួនឱ្យឯកជន ធ្វើជំនួស (Contract Out) ភាពជាដៃគូរដ្ឋ-ឯកជន (Public Private Partnership) ។ល។
- ការធ្វើទំនើបកម្មការងារសាធារណៈ សំដៅផងដែរលើការងាររបស់មន្ត្រីរាជការក្នុងនោះរួមមានការធ្វើវិមជ្ឈការការទទួលខុសត្រូវលើផ្នែកធនធានមនុស្ស ដើម្បីបង្កើនភាពទន់ភ្លន់ក្នុងការគ្រប់គ្រងការផ្តល់ប្រាក់កម្រៃ និងឧបត្ថម្ភតាមសមត្ថភាព និងការផ្លាស់ប្តូរនៅក្នុងមុខងារសាធារណៈ ។

ហេតុនេះ ការរៀបចំចងក្រងកម្រងព័ត៌មានសេវាសាធារណៈនេះ គឺជាជំហានដ៏សំខាន់មួយ ដើម្បីផ្តល់ព័ត៌មានចាំបាច់ពាក់ព័ន្ធនានាអំពីសេវាសាធារណៈនៅកម្ពុជា ឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព និងការទទួលខុសត្រូវខ្ពស់របស់ក្រសួង ស្ថាប័ននានា សំដៅបម្រើប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរឡើង ។

# ការប្រើប្រាស់កម្រងព័ត៌មានសេវាសាធារណៈ

## ១. អត្ថន័យកម្រងព័ត៌មានសេវាសាធារណៈ

កម្រងព័ត៌មានសេវាសាធារណៈ គឺជាឧបករណ៍មួយបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលបាននូវព័ត៌មានសេវាសាធារណៈឆាប់រហ័ស អាចជឿទុកចិត្តបាន និងជាក់ច្បាស់ មានន័យថាជាឧបករណ៍ផ្សារភ្ជាប់ទៅនឹងការពង្រឹងគណនេយ្យភាព តម្លាភាព និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ម្យ៉ាងទៀត ក្រសួង ស្ថាប័ន មានប្រព័ន្ធក្នុងការកែលម្អគុណភាព និងការផ្សព្វផ្សាយព័ត៌មានដែលមានការទាក់ទិនទៅនឹងយុត្តាធិការរបស់ខ្លួន ដោយធ្វើយ៉ាងណាយកចិត្តទុកដាក់ទៅលើ :

- ភាពងាយស្រួលក្នុងការយកសេវាទៅប្រើប្រាស់
- ភាពគួរសម រួសរាយ រាក់ទាក់ និងការយកចិត្តទុកដាក់ចំពោះអ្នកប្រើប្រាស់សេវា
- ការផ្តល់ចម្លើយងាយយល់នៅក្នុងថេរវេលា ដែលបានកំណត់ជាមុន និង
- ការផ្តល់ការបំភ្លឺរាល់ការទាមទាររបស់អ្នកប្រើប្រាស់សេវា ។

## ២. កម្មវត្ថុនៃកម្រងព័ត៌មានសេវាសាធារណៈ

កម្មវត្ថុសំខាន់ៗនៃកម្រងព័ត៌មានសេវាសាធារណៈ គឺ

- មានស្តង់ដារព័ត៌មានស្តីពី សេវាសាធារណៈនៅកម្ពុជា
- ជាឯកសារដែលអាចយកទៅអនុវត្តបានទាំងអ្នកប្រើប្រាស់សេវា និងអ្នកផ្តល់សេវា
- ធ្វើឱ្យកាន់តែងាយយល់នូវព័ត៌មានសេវាសាធារណៈនានា
- បម្រើប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរឡើង

## ៣. រចនាសម្ព័ន្ធនៃកម្រងព័ត៌មានសេវាសាធារណៈ

សេវាសាធារណៈនឹងត្រូវប្រមូលផ្តុំចងក្រងទៅតាមវិស័យ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន ស្របតាមគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈដែលបែងចែកសេវាសាធារណៈ ជា៧ប្រភេទធំៗដូចខាងក្រោម :

### ១. ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋ

ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋ គឺជាសេវាទទួលខុសត្រូវផ្ទាល់មុខរបស់រដ្ឋដែលផ្តល់ដោយអង្គភាពរដ្ឋ ឬនីតិបុគ្គលនៃនីតិសាធារណៈ ដែលរដ្ឋបានប្រគល់សិទ្ធិអំណាចឱ្យដើម្បីអនុវត្ត។ ចង្កោមសេវាពាក់ព័ន្ធ

និងអធិបតេយ្យភាពរដ្ឋមានដូចជា លិខិតអនុញ្ញាត អាជ្ញាប័ណ្ណ បញ្ជីអត្រានុកូលដ្ឋាន សំបុត្របញ្ជាក់ កំណើត ប័ណ្ណសំគាល់យានយន្ត អាកាសយាន និងនាវា វិញ្ញាប័ណ្ណប័ត្រទទួលស្គាល់កម្មសិទ្ធិ អត្តសញ្ញាណប័ណ្ណ ប្រជាពលរដ្ឋខ្មែរ សៀវភៅគ្រួសារ ការធ្វើនីត្យានុកូលកម្មជាដើម ។

ពាក់ព័ន្ធទៅនឹងចង្កោមនៃសេវាសាធារណៈនេះ ការរៀបចំ និងការប្រតិបត្តិការនៃការផ្តល់សេវាត្រូវទទួលខុសត្រូវដោយរដ្ឋ ឬភ្នាក់ងាររបស់រដ្ឋ ។

## ២. ចង្កោមសេវាពាក់ព័ន្ធនឹងផ្នែកសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម

ចង្កោមសេវាពាក់ព័ន្ធផ្នែកសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការស្នាក់នៅ ការធ្វើដំណើរការប្រាស្រ័យទាក់ទងរបស់ប្រជាពលរដ្ឋ និងសុវត្ថិភាពសង្គម គឺជាសមត្ថកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ច នគរបាលជាតិ កងរាជអាវុធហត្ថ និងកងយោធពលខេមរភូមិន្ទគ្រប់លំដាប់ថ្នាក់ទូទាំងប្រទេស ។ ចង្កោមសេវានេះជាសេវាដ៏ចាំបាច់ និងមិនអាចខ្វះបាន ដើម្បីធានាបរិយាកាសល្អដល់ការអភិវឌ្ឍសង្គមជាតិ ការកាត់បន្ថយភាពក្រីក្រ ភាពសុខសាន្តរបស់ប្រជាពលរដ្ឋ និងជាទំនុកចិត្តដល់វិនិយោគិន ធុរជន ក្នុងការប្រកបរបរអាជីវកម្ម និងជំនួញជួញដូរ ។

ពាក់ព័ន្ធទៅនឹងចង្កោមនៃសេវាសាធារណៈនេះ ការរៀបចំ និងការប្រតិបត្តិការនៃការផ្តល់សេវាត្រូវធ្វើឡើងដោយរដ្ឋ ឬភ្នាក់ងាររបស់រដ្ឋ ។

## ៣. ចង្កោមសេវាពាក់ព័ន្ធនឹងយុត្តិធម៌ និងអាជ្ញាកណ្តាល

ចង្កោមសេវាពាក់ព័ន្ធនឹងយុត្តិធម៌ និងអាជ្ញាកណ្តាល ដូចជា វិវាទរវាងប្រជាពលរដ្ឋ និងប្រជាពលរដ្ឋ ឬរវាងប្រជាពលរដ្ឋ និងអ្នករាជការ ឬរវាងប្រជាពលរដ្ឋ និងផ្នែកឯកជន ឬរវាងអ្នករាជការ និងផ្នែកឯកជន ជាដើម សេវាដោះស្រាយវិវាទនេះធ្វើឡើងតាមរូបភាព ២ យ៉ាង ៖

- តាមរយៈក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលជាអ្នកសម្របសម្រួល និងដោះស្រាយចំពោះករណីវិវាទមិនធ្ងន់ធ្ងរ ដើម្បីសម្រួលដល់គូភាគីទាំងសងខាង ដោយមិនចាំបាច់ពឹងផ្អែកតែទៅលើតុលាការ និងកាត់បន្ថយការកកស្ទះសំណុំរឿងនៅតុលាការ ។
- ក្នុងករណីគូភាគីវិវាទ មិនទទួលយកនូវដំណោះស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេនោះ ការដោះស្រាយវិវាទ ត្រូវធ្វើឡើងតាមរយៈតុលាការ ។

ភាពជឿទុកចិត្តរបស់អ្នកប្រើប្រាស់សេវា និងអ្នកពាក់ព័ន្ធទាំងអស់ អាស្រ័យទៅលើការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ នៅក្នុងបរិបទនៃនីតិរដ្ឋ ។ ដូចនេះ រាល់សកម្មភាពកែលម្អប្រព័ន្ធការងារទាំងអស់ត្រូវរៀបចំឡើងជាជំហានៗ និងដោយប្រុងប្រយ័ត្ន ក្នុងទិសដៅបង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាកម្មយុត្តិធម៌ ។

## ៤. ចង្កោមសេវាពាក់ព័ន្ធនឹងការលើកកម្ពស់កិច្ចការពាណិជ្ជកម្ម សហគ្រាសធុនតូច និង

## មធ្យម បរិស្ថានវិនិយោគ និងការចូលរួមរបស់ផ្នែកឯកជនក្នុងការកសាង និងការថែទាំហេដ្ឋារចនាសម្ព័ន្ធ

### ក- ការលើកកម្ពស់កិច្ចការពាណិជ្ជកម្ម

រាជរដ្ឋាភិបាល ដែលជាអ្នករៀបចំយុទ្ធសាស្ត្រ និងជាអ្នកគ្រប់គ្រងការអភិវឌ្ឍ ដើម្បីធ្វើឱ្យបរិស្ថានធុរកិច្ចកាន់តែប្រសើរសម្រាប់វិស័យឯកជន បានចាត់ទុកវិស័យឯកជនជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច។ អាទិភាពជាពិសេសនឹងត្រូវផ្តោតទៅលើការរៀបចំឱ្យកាន់តែប្រសើរឡើងនូវបរិស្ថានរួម សម្រាប់ការអភិវឌ្ឍវិស័យឯកជន តាម រយៈវិធានការជាក់ស្តែងនានា :

១- ពង្រឹងអភិបាលកិច្ចល្អ ទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន។

២- កាត់បន្ថយរាល់បែបបទស្មុគ្រស្មាញ និងវែងអន្លាយ នៅតាមក្រសួងស្ថាប័នដែលពាក់ព័ន្ធដល់ការនាំចេញ នាំចូល។

៣- បំបាត់ចោលនូវភារកិច្ចជាន់គ្នារបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញដំណើរការត្រួតពិនិត្យតែមួយកន្លែងឱ្យមានប្រសិទ្ធភាព។

៤- ពង្រឹងការអនុវត្តយន្តការការិយាល័យ "ច្រកចេញ ចូលតែមួយ" នៅតាមបណ្តាច្រកអន្តរជាតិ។

### ខ-សហគ្រាសធុនតូច និងមធ្យម :

រាជរដ្ឋាភិបាល បន្តជំរុញការអភិវឌ្ឍសហគ្រាស ធុនតូច និងមធ្យមតាមរយៈគោលនយោបាយ :

១- លើកទឹកចិត្តដល់សហគ្រាសធុនតូច និងមធ្យម ជាពិសេសតាមរយៈការផ្តល់ឥណទាន រយៈពេលមធ្យម និងរយៈពេលវែង

២- ទប់ស្កាត់ការរត់គេចពន្ធគ្រប់ប្រភេទ

៣- កាត់បន្ថយបែបបទការចុះបញ្ជី និងការរៀបចំដំណើរការក្រុមហ៊ុន

៤- សម្រួលដល់ការនាំចេញ នាំចូល តាមរយៈការកាត់បន្ថយបែបបទស្មុគ្រស្មាញក្នុងការស្នើសុំ អាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតផ្សេងៗ ។ល។

៥- កាត់បន្ថយពេលវេលា និងកាត់បន្ថយថ្លៃសេវាកម្មក្នុងការអនុញ្ញាតឱ្យដំណើរការផលិតកម្មនៃសហគ្រាសធុនតូច និងមធ្យម តាមរយៈការអនុវត្តយន្តការការិយាល័យច្រកចេញ ចូលតែមួយ

៦- ផ្តល់ការគាំពារដល់សហគ្រាសមួយចំនួនក្នុងរយៈពេលមួយសមស្រប

៧- ជំរុញឱ្យមានសម្ព័ន្ធភាពរវាងសហគ្រាសធុនតូច និងមធ្យម ជាមួយនឹងឧស្សាហកម្មធុនធំ ជាដើម។

ដើម្បីសម្រេចគោលដៅខាងលើ រាជរដ្ឋាភិបាលយកចិត្តទុកដាក់ :

១- ជំរុញលើកទឹកចិត្តដល់ការផលិតទំនិញបម្រើទីផ្សារក្នុងស្រុកជំនួសការនាំចូល ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រនៃការបង្កើតមូលដ្ឋាន ផលិតកម្មទំនិញក្នុងប្រទេសឱ្យបានច្រើន ស្របទៅនឹងយុគសម័យនៃតំបន់ភាវូបនីយកម្ម និងសកលភាវូបនីយកម្ម

២- រៀបចំយុទ្ធសាស្ត្របង្កើនសមត្ថភាពប្រកួត ប្រជែងសម្រាប់សហគ្រាសធុនតូច និងមធ្យម

៣- រៀបចំផែនការសកម្មភាព និងបទប្បញ្ញត្តិនានា ដើម្បីគ្រប់គ្រង តាមដានត្រួតពិនិត្យ និងគាំទ្រដល់ដំណើរការរបស់សហគ្រាសធុនតូច និងមធ្យម ។

**គ- បរិស្ថានវិនិយោគ និងការចូលរួមផ្នែកឯកជនក្នុងការកសាង និងថែទាំហេដ្ឋារចនាសម្ព័ន្ធ**

ពាក់ព័ន្ធនឹងការងារនេះ រាជរដ្ឋាភិបាលនឹងចាត់វិធានការចាំបាច់ ដើម្បីពង្រឹង និងកែលម្អបរិស្ថានវិនិយោគ និងធុរកិច្ច រួមមាន គោលនយោបាយលើកទឹកចិត្ត លិខិតបទដ្ឋានសម្រាប់ណែនាំ និងជំរុញការចូលរួមរបស់ផ្នែកឯកជនក្នុងការកសាង និងថែទាំហេដ្ឋារចនាសម្ព័ន្ធ ។

រចនាសម្ព័ន្ធនៃផ្នែកពាក់ព័ន្ធទៅនឹងចង្កោមសេវានេះ ដែលមិនទាន់អាចឆ្លើយតបបានទៅនឹងតម្រូវការជាចាំបាច់ក្នុងការសម្រួលដល់ការធ្វើអាជីវកម្ម ការវិនិយោគទុន និងការអភិវឌ្ឍផ្នែកឯកជន ត្រូវធ្វើការ កែសម្រួលឱ្យបានសមស្រប និងឱ្យបានឆាប់រហ័ស ទៅតាមស្ថានភាពជាក់ស្តែង និងធនធានដែលមាន ។

## ៥. ចង្កោមសេវាសង្គមកិច្ច វប្បធម៌ និងកិច្ចការនារី

ចង្កោមសេវានេះ រួមមានសេវាអប់រំ (លើកកម្ពស់គុណភាពសេវាអប់រំសម្រាប់ទាំងអស់គ្នា សំភារៈសិក្សាគ្រប់គ្រាន់ និងសិទ្ធិទទួលបានសេវាអប់រំជាមូលដ្ឋាន) សេវាអនាម័យ និងសុខភាព (បង្កលក្ខណៈងាយស្រួល គុណភាព ប្រសិទ្ធភាព ដើម្បីផ្តត់ផ្គង់សេវាសុខាភិបាលមូលដ្ឋានប្រកបដោយសមធម៌ និងនិរន្តរភាពជូនប្រជាពលរដ្ឋ គ្រប់រូបជាពិសេសជនក្រីក្រ និងក្រុមជនងាយរងគ្រោះ) សេវាសម្រាប់ការកំសាន្ត សេវាសង្គមកិច្ច សេវាគាំពារ កុមារកំព្រា កុមារងាយរងគ្រោះ ជនពិការ សេវាលើកស្ទួយ និងការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសេវាដទៃទៀត ដែលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ។

## ៦. ចង្កោមសេវាពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

ការផ្តល់សេវានៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត គឺជាអាទិភាពចំបងមួយរបស់រាជរដ្ឋាភិបាលដើម្បីជំរុញ និងបង្កើនល្បឿនកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ។

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ត្រូវផ្តោតជាសំខាន់លើការបន្តការកសាងប្រព័ន្ធគមនាគមន៍ដឹកជញ្ជូន រួមមាន ផ្លូវថ្នល់ ស្ពាន ផ្លូវដែក ផ្លូវទឹក កំពង់ផែ និងអាកាសយានដ្ឋាន ដែលអាចតភ្ជាប់ទីក្រុងទៅជនបទ និងគ្រប់ទីកន្លែងទូទាំងប្រទេស កសាងមន្ទីរ ពេទ្យ សាលារៀន អណ្តូងទឹក ប្រព័ន្ធទឹកស្អាត ប្រព័ន្ធធារាសាស្ត្រ អគ្គិសនី

ថាមពល បច្ចេកវិទ្យាព័ត៌មាន ប្រៃសណីយ៍ និងទូរគមនាគមន៍។ល។ ពាក់ព័ន្ធនឹងចង្កោមសេវានេះ រាជរដ្ឋាភិបាលមានគោលនយោបាយលើកទឹកចិត្តឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេស ផ្នែកឯកជន។

**៧. ចង្កោមសេវាពាក់ព័ន្ធនឹងការប្រមូលចំណូល ការធ្វើវិចារណកម្មចំណាយ និងការបើកផ្តល់**

ចង្កោមសេវានេះ ពាក់ព័ន្ធនឹងការកែលម្អការគ្រប់គ្រងចំណូល ចំណាយ និងការបើកផ្តល់ឱ្យមានតម្លាភាព និងប្រសិទ្ធភាពខ្ពស់ជាងមុន សំដៅកាត់បន្ថយការលំបាករបស់អ្នកប្រើប្រាស់សេវា។

ដើម្បីសម្រួលដល់ការអនុវត្ត ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល នឹងធ្វើការសហការយ៉ាងជិតស្និទជាមួយក្រសួង ស្ថាប័នដែលមានភារកិច្ចពាក់ព័ន្ធនឹងចង្កោមសេវាទាំងអស់ខាងលើ ដើម្បីរៀបចំចងក្រងបញ្ជីសេវានេះឱ្យបានសមស្រប។

## ៤-ការទទួលខុសត្រូវក្នុងការធ្វើបច្ចុប្បន្នភាពព័ត៌មាន

បណ្តាក្រសួង ស្ថាប័ននានា ត្រូវទទួលខុសត្រូវក្នុងការកែលម្អគុណភាព និងការផ្សព្វផ្សាយព័ត៌មានដែលមានការទាក់ទិនទៅនឹងសេវានានាដែលខ្លួនមានយុត្តាធិការ។

## ៥-តើមានឯកសារអ្វីខ្លះដែលអាចរកមើលបាន?

ក្នុងចំណោមឯកសារដែលអាចរកមើលជាបឋម នៅក្នុងកម្រងព័ត៌មានសេវាសាធារណៈនេះ **គឺចង្កោមសេវាទី២ ទី៥ ទី៦ និង ទី៧** ដោយឡែកចង្កោមសេវាទាំងអស់នឹងត្រូវធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ ដោយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល មានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័ននានា។

ចង្កោមសេវាទី ២ ៥ ៦ និង ៧ នេះ ត្រូវបានចងក្រង មានដូចតទៅ :

# ចង្កោមសេចក្តីទី ២

# ក្រសួងការពារជាតិ


មហាវិថីសហព័ន្ធរុស្ស៊ី កាច់ជ្រុងផ្លូវ ១៧៥ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០២៣ ៨៨៣ ១៨៤ ៤២៨ ១៧១

ទូរសារ : ០២៣ ៨៨៣ ១៨៤

អ៊ីម៉ែល : info@mond.gov.kh

វិបសាយ : http://www.mond.gov.kh

# ទំព័រព័ត៌មានសេវាអប់រំបន្សាបសារធាតុគ្រឿងញៀន

| | |
|---|---|
| ឈ្មោះសេវា | ទំព័រព័តិមានសេវាអប់រំបន្សាបសារធាតុគ្រឿងញៀន |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងការពារជាតិ<br>• កងរាជអាវុធហត្ថ ខេត្តបាត់ដំបង<br>• ទូរស័ព្ទលេខ : ០១៦ ៥០០ ១៦៣ FRE ( ៥៤៣ ) ០១៦ ៩៩៤ ៨៤៨ ០៩៧ ៧៧៧ ៧៧ ៨២ /០៩៧ ៩៨៥ ៥៨ ០២ /០១៦ ៩៧ ៧៩ ៧៩ ០១២ /៨២៣ ៦៦៨<br>• កងរាជអាវុធហត្ថ ខេត្តបន្ទាយមានជ័យ<br>• ទូរស័ព្ទលេខ : ០១២ ៨១៥ ០០៧ FRE (៥៧០) ០១១/០១២ /០១៥ ៩៩៨ ៩៦៦/០៩៧ ៧៧៧ ៧៧ ៨៤/០៩៧ ៩៩៨ ៣១ ២៣ |
| គោលបំណង<br>នៃការផ្តល់សេវា | • អប់រំបន្សាបសារធាតុគ្រឿងញៀនដល់ជនទាំងឡាយដែលកំពុងរងគ្រោះដោយសារគ្រឿងញៀន |
| មូលដ្ឋានគតិយុត្ត | |
| អតិថិជនដែលមានសិទ្ធិ<br>ទទួលសេវា | • គ្រប់ប្រជាពលរដ្ឋទូទាំងប្រទេស ឬជនបរទេស |
| ស្តង់ដារសេវា | |
| តម្រូវការឯកសារ | |
| យោបល់ | • គ្រប់ជនរងគ្រោះដោយសារគ្រឿងញៀនអាចទំនាក់ទំនងទៅកងរាជអាវុធហត្ថខេត្តបាត់ដំបង ឬកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ តាមលេខទូរសព្ទ័ខាងលើ ២៤ លើ ២៤ម៉ោង |

# ទំព័រព័ត៌មានរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម

| ឈ្មោះសេវា | ទំព័រព័ត៌មានរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម |
|---|---|
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងការពារជាតិ<br>១,កងរាជអាវុធហត្ថលើផ្ទៃប្រទេស<br>ស្នងការដ្ឋានស្រាវជ្រាវ និងយុត្តិធម៌<br>ទូរស័ព្ទលេខ : ០១២ ៦៧២ ០១២ /០១៦ ៥០០ ១៧២ /០៩៧ ៧៧៧ ៧៧ ៧២<br>០១១ ៨១ ៧៧ ៧៧ /០១២ ៧២ ៦៦ ៦៦ /០១២ ៨៣៧ ៩៨០<br><br>ស្នងការដ្ឋានព័ត៌មានសន្តិសុខ<br>ទូរស័ព្ទលេខ : ០១៦ ៩៦ ៩៩ ៩៩/០១២ ៨៤ ០៤ ៦៧/០១២ ៨៩ ៨៩ ៥៨<br>០១២ ៣៣ ៧៧ ៧៧/០១៧ ៥៦ ៨២ ៧៨<br><br>២,កងរាជអាវុធហត្ថរាជធានីភ្នំពេញ<br>ទូរស័ព្ទលេខ : ០១២ ៨៤០ ៤១២ /០៩៧ ៧៧៧ ៧៧ ៦០/ ០១២ ៣០៦ ៣០៦<br>Fre (៥៤៣) ០១២ ៨៤០ ៣៧២ Fre (៥២១) ០១២ ៦៤៦ ៦៣៦<br><br>៣,កងរាជអាវុធហត្ថខេត្ត កណ្តាល<br>ទូរស័ព្ទលេខ : ០១២ ៩០០ ៦៦៦ / ០១៦ ៥០០ ១៥៨ /០៩៧ ៧៧៧ ៧៧ ៦១<br>០៩៧ ៩៩២ ៣៣ ៣៩ Fre (៥៨៤)/០១២ ៥១១ ១៤៧<br>០៩៧ ៩៩២ ៣៣ ៩៣ Fre (៥៥០) ០១២ ២៧០ ២៧០<br><br>៤,កងរាជអាវុធហត្ថខេត្ត សៀមរាប<br>ទូរស័ព្ទលេខ : ០១២ ៨៥២ ២២៩ Fre (៥៦៧)/០៩៧ ៧៧៧ ៧៧ ៧៨<br>០១២ ៥៧ ៥៧ ៦៧<br><br>៥,កងរាជអាវុធហត្ថខេត្ត កំពង់ស្ពឺ<br>ទូរស័ព្ទលេខ : ០១៦ ៥០០ ១៥៩ Fre (៥៤៥)/០៩៧ ៧៧៧ ៧៧ ៧៣<br>០១២ ៨៨៨ ៥១០ |

៦.កងរាជអាវុធហត្ថខេត្ត កំពង់ឆ្នាំង

ទូរស័ព្ទលេខ : ០១២ ៩១២ ៥៥២ Fre (៥៤៦) / ០៩៧ ៧៧៧ ៧៧ ៦២

០១២ ៦៣៥ ៣០៧/០៩៧ ៩៩៦ ០៣ ០៧

៧.កងរាជអាវុធហត្ថខេត្ត កំពត

ទូរស័ព្ទលេខ : ០១២ ៣០០ ៤៤៤ Fre (៦១៨) / ០៩៧ ៧៩៧ ៥៩ ៧៥

០១៦ ៥០០ ១៦០

៨.កងរាជអាវុធហត្ថខេត្ត ពោធិ៍សាត់

ទូរស័ព្ទលេខ : ០១២ ៧១៣ ២៤២/០១៦ ៥០០ ១៥៣ /០៩៧ ៧៧៧ ៧៧ ៨១

០១២ ៨៣៨ ៨២៥ /០៩៧ ៧២៥ ៩៩ ១១

៩.កងរាជអាវុធហត្ថខេត្ត ប៉ៃលិន

ទូរស័ព្ទលេខ : ០១២ ៨៣៩ ១២២/០១៦ ៥០០ ១៧៥ /០៩៧ ៧៧៧ ៧៧ ៨៣

១០.កងរាជអាវុធហត្ថខេត្ត ព្រះវិហារ

ទូរស័ព្ទលេខ : ០១១ ៩៤១ ១១២ /០១២ ៩១៤ ៦៣៨

០១៦ ៥០០ ១៨៥/០៩៧ ៧៧៧ ៧៧ ២៥

០១២ ៩៣០ ៥៤៧ /០៩៧ ៧៥៧ ៨៨ ៥៥

១១.កងរាជអាវុធហត្ថខេត្ត ព្រះសីហនុ

ទូរស័ព្ទលេខ : ០១៦ ៥០០ ១៦២ Fre ( ៥៦៩) /០៩៧ ៧៧៧ ៧៧ ៧៤

០១២ ៤១៨ ១០១/០៩៧ ៧៦៨ ៦៦ ១១

១២.កងរាជអាវុធហត្ថខេត្ត កោះកុង

ទូរស័ព្ទលេខ : ០១២ ២៥០ ៧៤៨ /០១៦ ៥០០ ១៦៤ Fre (៥៩៣)

០៩៧ ៧៧៧ ៧៧ ៧៥/០៩៧ ៧១៧ ៩៩ ៧៧ Fre (៥៧៦)

១៣.កងរាជអាវុធហត្ថខេត្ត តាកែវ

ទូរស័ព្ទលេខ : ០១៦ ៥០០ ១៦១ Fre (៥៤៤) /០៩៧ ៧៧៧ ៧៧ ៧០

០១២ ៤៦៤ ៤៤៤/០៩៧ ៩៩៦ ៦៩ ៥៩

១៤.កងរាជអាវុធហត្ថខេត្ត កំពង់ធំ

ទូរស័ព្ទលេខ : ០១២ ៧០៥ ៦៩៩/០៩៧ ៧៧៧ ៧៧ ៧៦

០១២ ៨២៩ ៩៣៦ Fre (៥៤១)/០៩៧ ៧៥៨ ៦៦ ១១

១៥.កងរាជអាវុធហត្ថខេត្ត ក្រចេះ

ទូរស័ព្ទលេខ : ០១២ ៨៤២ ៦២៦ /០១៦ ៥០០ ១៩៧ /០៩៧ ៨៩៨ ៩៨ ៩៨

០១២ ៩៥២ ០៦៦/០៩៧ ៧៥៨ ៩៩ ៧៧

១៦.កងរាជអាវុធហត្ថខេត្ត រតនៈគិរី

ទូរស័ព្ទលេខ :   ០១២ ៨៣០ ៤៤៦០/១៦ ៥០០ ១៥៤

០៩៧ ៧៧៧ ៧៧ ៦៣ /០៩៧ ៧៦១ ៦៦ ៣៣

០១១ ២៩៣ ៨៤៤/០១២ ៤៣៥ ៥៦១

១៧.កងរាជអាវុធហត្ថខេត្ត មណ្ឌលគិរី

ទូរស័ព្ទលេខ : ០១២ ៨២១ ២៧៥/០១៦ ៥០០ ១៧៣/០៨៩ ៩១៣ ៩៨៩

០៩៧ ៧៧៧ ៧៧ ៦៤ /០៩៧ ៧៧១ ៧៧ ៥៥

១៨.កងរាជអាវុធហត្ថខេត្ត ស្វាយរៀង

ទូរស័ព្ទលេខ : ០១១ ៨៧៧ ៤៨៥ / ០១៦ ៥០០ ១៨៣

០៩៧ ៧៧៧ ៧៧ ៦៧ /០១៥ ៣៨៤ ៦០៦ Fre (៥៤២)

១៩.កងរាជអាវុធហត្ថខេត្ត ព្រៃវែង

ទូរស័ព្ទលេខ : ០១៦ ៥០០ ១៧១ Fre (៥៧៩) / ០៩៧ ៧៧៧ ៧៧ ៦៩

០១២/០១៦ ៩០៧ ០០៨ Fre (៥៩៧)

២០.កងរាជអាវុធហត្ថខេត្ត កំពង់ចាម

ទូរស័ព្ទលេខ : ០១២ ៥៦១ ៧៨៩ Fre (៥៤៧) / ០៩៧ ៧៧៧ ៧៧ ៦៨

០១២ ៩៤០ ៩៩៥/០៩៧ ៩៩៥ ៥៥ ៧៥

២១.កងរាជអាវុធហត្ថខេត្ត ឧត្តរមានជ័យ

ទូរស័ព្ទលេខ :០១១ ៧១៣ ០៤៣/០១២ ៨៣៧ ១៥៣/០៩៧ ៧៧៧ ៧៧៨០

| | |
|---|---|
| | ០១៦ ៥០០ ១៨២/០១១ ៦៣១ ២៨៥/០១៦ ២៧៩ ៣៧៤<br><br>២២.កងរាជអាវុធហត្ថខេត្ត ស្ទឹងត្រែង<br>ទូរស័ព្ទលេខ  : ០១២ ៧៧២ ៧៧២ / ០១៦ ៥០០ ១៧០<br>០៩៧ ៧៧៧ ៧៧ ៦៦ / ០១២ ៩១៩ ៣៤២<br><br>២៣.កងរាជអាវុធហត្ថខេត្ត កែប<br>ទូរស័ព្ទលេខ : ០១២ ៨០២ ៥១៣/០១៦ ៥០០ ១៨១/០៩៧ ៧៧៧ ៧៧៧១<br>០១២ ៦៦៧ ៤០៧ / ០៩៧ ៩៨៨ ០៨ ៨៩ |
| គោលបំណង<br>នៃការផ្តល់សេវា | ធានាបរិយាកាស  ការអភិវឌ្ឍសង្គមជាតិ   រក្សាភាពសុខសាន្តរបស់ប្រជាពលរដ្ឋ និងផ្តល់ទំនុកចិត្តដល់វិនិយោគិន ធុរជន ក្នុងការប្រកបអាជីវកម្មនៅកម្ពុជា |
| មូលដ្ឋានគតិយុត្ត | អនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងទូទៅ នៃកងរាជអាវុធហត្ថ |
| អតិថិជនដែលមានសិទ្ធិ<br>ទទួលសេវា | គ្រប់ប្រជាពលរដ្ឋទូទាំងប្រទេស ឬជនបរទេស |
| ស្តង់ដារសេវា | |
| តម្រូវការឯកសារ<br>ដើម្បីទទួលបានសេវា | |
| យោបល់ | ប្រជាពលរដ្ឋគ្រប់រូបដែលបានជួបប្រទះនូវរាល់អំពើអយុត្តិធម៌     ដែលបង្កភាពអសន្តិសុខណាមួយ អាចទំនាក់ទំនងទៅកងរាជអាវុធហត្ថ ២៤ ខេត្ត-ក្រុង |

# ចង្កោមសេវាទី ៥

# ក្រសួងអភិវឌ្ឍន៍ជនបទ

អាសយដ្ឋាន : កាច់ជ្រុងវិថីលេខ ១៦៩ មហាវិថីសហព័ន្ធរុស្ស៊ី

សង្កាត់ មិត្តភាព ខណ្ឌ ៧ មករា រាជធានីភ្នំពេញ

ទូរស័ព្ទ : (៨៥៥ ២៣ )៨៨៤ ៥៣៩

ទូរសារ : (៨៥៥ ២៣ )៩៩១ ១១៧



ប្រអប់សំបុត្រ : ២០១៦



គេហទំព័រ : www.mrd.gov.kh

# គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទនៅខេត្តកំពង់ចាម
## ( ការផ្តល់សេវាឥណទាន ជនបទ )

| | |
|---|---|
| ឈ្មោះសេវា | គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទនៅខេត្តកំពង់ចាម (ការផ្តល់សេវាឥណទាន ជនបទ) |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងអភិវឌ្ឍន៍ជនបទ<br>• នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ<br>- អាសយដ្ឋាន : កាច់ជ្រុងវិថីលេខ ១៦៩ និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ<br>- ទូរស័ព្ទ: ៨៥៥-២៣ ៤២៧ ៣២៧<br>- ទូរសារ: ៨៥៥-២៣ ៤២៧-៣២៧<br>- គេហទំព័រ : www.mrd.gov.kh<br>• មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម<br>- អាសយដ្ឋាន : ផ្លូវកេតុមាលា ភូមិទី ១៤ សង្កាត់កំពង់ចាម ស្រុកកំពង់ចាម ខេត្តកំពង់ចាម<br>- ទូរស័ព្ទ: (៨៥៥-៤២) ៩៤១ ៩៦០<br>- ទូរសារ: (៨៥៥-៤២) ៩៤១ ៨៦០ |
| គោលបំណង នៃការផ្តល់សេវា | • ផ្តល់ប្រាក់កម្ចីដល់ប្រជាពលរដ្ឋជនបទសម្រាប់ជាដើមទុន ដើម្បីប្រកបមុខរបរ បង្កើនប្រាក់ចំណូល |
| មូលដ្ឋានគតិយុត្ត | • វិញ្ញាបនបត្រលេខ ០៣០ រ.ប.ច.ប ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៩ ស្តីពីការទទួលស្គាល់ជាប្រតិបត្តិករឥណទានជនបទរបស់ធនាគារជាតិនៃកម្ពុជា |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | • ប្រជាពលរដ្ឋនៅទីជនបទ ដែលមានអាយុពី ១៨ឆ្នាំ ដល់ ៦៥ឆ្នាំ ដែលមានសមត្ថភាព សងប្រាក់ត្រឡប់មកវិញ |
| ស្តង់ដារសេវា | • ឥណទានជាក្រុម : សមាជិកពី ០៣នាក់ ទៅ ០៦នាក់សម្រាប់ធានាគ្នាទៅវិញទៅមក<br>- ទំហំឥណទាន : មិនលើសពី ៥០០ ០០០រៀល (ហាសិបម៉ឺនរៀល)<br>- រយៈពេលខ្ចី : ពី ០៦ខែ ទៅ ១០ខែ |

| | |
|---|---|
| | - របៀបសង : រំលួស និង ដុល<br>- អត្រាការប្រាក់ : ២,៤% ក្នុងមួយខែ ( ពីរចុចបួនភាគរយក្នុងមួយខែ)<br>• ឥណទានឯកក្កជន ( ទោល ) :<br>- ទំហំឥណទាន : ពី ៥០០ ០០០រៀល ដល់ ១២ ០០០ ០០០រៀល ( ហាសិបម៉ឺនរៀល ដល់ដប់ពីរលានរៀល )<br>- រយៈពេលខ្ចី : ពី ០៦ខែ ទៅ ២៤ ខែ<br>- របៀបសង : រំលួសចាប់ពីខែទី ០៦<br>- អត្រាការប្រាក់ : ២.២% ក្នុងមួយខែ ( ពីរចុចពីរភាគរយក្នុងមួយខែ)<br>- វត្ថុបញ្ចាំ : ត្រូវមានតម្លៃ ២០០% ( ពីររយភាគរយ) នៃទំហំឥណទាន<br>- ដំណើការសេវា : ចាប់ពីពេលដាក់ពាក្យសុំខ្ចីឥណទានរហូតដល់ពេលបញ្ចេញទឹកប្រាក់ឱ្យខ្ចី មិនលើសពីចំនួន ០៥ថ្ងៃធ្វើការ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | ចំពោះសេវាឥណទានជាក្រុម<br>• ពាក្យសុំខ្ចីរបស់ក្រុមធានា<br>• កិច្ចសន្យាខ្ចីប្រាក់របស់ក្រុមធានា<br>ចំពោះសេវាឥណទានឯកត្តជន ( ទោល)<br>• ពាក្យសុំខ្ចីចងការប្រាក់<br>• កិច្ចសន្យាខ្ចីប្រាក់<br>• កិច្ចសន្យាដាក់បញ្ចាំ<br>• កិច្ចសន្យាព្រមព្រៀងធានា<br>• លិខិតបញ្ជាក់អចលនទ្រព្យ |
| យោបល់ | • ការផ្តល់ឥណទានជនបទពីគម្រោង MRD-CS ដែលមានអត្រាការប្រាក់ទាប នឹងអាចផ្តល់ដើមទុនសម្រាប់រក្សា-បង្កើត និងពង្រីងមុខរបរផលិតកម្មកសិកម្ម សិប្បកម្ម សហគ្រាស ខ្នាតតូច និងអាជីវកម្ម ផ្សេងៗ និងសហការបង្កើនប្រាក់ចំណូល ក៏ដូចជាការរួមចំណែកកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ហើយដែលគម្រោងនេះនឹងពង្រីងបន្ថែមទៅតាមបណ្តាខេត្តផ្សេងៗទៀត |

# សាងសង់ប្រើប្រាស់បង្គន់អនាម័យ និងការប្រតិបត្តិអនាម័យល្អ

| | |
|---|---|
| ឈ្មោះសេវា | សាងសង់ប្រើប្រាស់បង្គន់អនាម័យ និងការប្រតិបត្តិអនាម័យល្អ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងអភិវឌ្ឍន៍ជនបទ<br>• នាយកដ្ឋានថែទាំសុខភាពជនបទ<br>• អាសយដ្ឋានៈ កាច់ជ្រុងវិថីលេខ១៦៩ និងមហាវិថីសហពន្ធ័រុស្សី រាជធានីភ្នំពេញ<br>• ទូរស័ព្ទ : (៨៥៥-២៣) ៣៦៦ ៦២៧<br>• ទូរសារ : (៨៥៥-២៣) ៨៨១ ០៩៣<br>• សារអេឡិចត្រូនិច : cheassamnang@online.com.kh<br>• គេហទំព័រ : www.mrd.gov.kh |
| គោលបំណង នៃការផ្តល់សេវា | • លើកកម្ពស់អនាម័យល្អក្នុងការរស់នៅ ដើម្បីទប់ស្កាត់ និងកាត់បន្ថយអត្រាឈឺ និងស្លាប់ដែលបណ្តាលពីកង្វះអនាម័យ |
| មូលដ្ឋានគតិយុត្ត | • គោលនយោបាយជាតិស្តីពី វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ<br>• អនុក្រឹត្យលេខ ៥២.អនក្រ.បក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០ស្តីពីការកំណត់ទិវាជាតិលើកកំពស់អនាម័យជនបទ |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | • ប្រជាពលរដ្ឋទូទៅ នៅតាមសហគមន៍ជនបទ នៃព្រះរាជាណាចក្រកម្ពុជា |
| ស្តង់ដារសេវា | • ចុះធ្វើការវាយតម្លៃជាក់ស្តែងទៅលើស្ថានភាពអនាម័យតាមភូមិ (០១ ថ្ងៃ/ភូមិ)<br>• បង្កើតបណ្តាញភ្នាក់ងារស្ម័គ្រចិត្តសុខភាពភូមិ និងបណ្តុះបណ្តាល (០២ ដង/វគ្គ)<br>• បើកវគ្គបណ្តុះបណ្តាលចំពោះមន្ត្រីបុគ្គលិកមន្ទីរអភិវឌ្ឍន៍ជនបទខេត្តគោលដៅ (០៥ ថ្ងៃ ក្នុងមួយវគ្គ )<br>• ចុះអប់រំអនាម័យផ្ទាល់តាមភូមិដោយមន្ត្រីមន្ទីរអភិវឌ្ឍន៍ជនបទ (០២ ដង/១ខែ)<br>• ផលិតសម្ភារអប់រំ និងផ្គត់ផ្គង់សម្ភារបណ្តុះបណ្តាល |

| | |
|---|---|
| | • ប្រជាពលរដ្ឋនឹងទទួលបានការឧបត្ថម្ភក្នុងការផ្តល់សម្ភារសាងសង់បង្គន់អនាម័យរួមមាន ៖ លូ ០៣កង់, គម្របលូស្តុប, ចានព័រសឺលែន, ផែន, លូបង្ហូរ និងទុយោបង្ហុយ<br>• តាមដានការអនុវត្តគម្រោង<br>• រៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយអំពីអនាម័យ<br>• សម្របសម្រួល ការប្រជុំផ្លាស់ប្តូរបទពិសោធន៍<br>• វាយតម្លៃទីផ្សារ អំពីការផ្គត់ផ្គង់ និងតម្រូវការ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | • ពាក្យសុំដែលបញ្ជាក់ពីការស្ម័គ្រចិត្តសាងសង់បង្គន់អនាម័យដោយចុះឈ្មោះជាមួយនឹងមេភូមិ<br>• កិច្ចសន្យាចូលរួមបដិភាគ (ជាសម្ភារ ពលកម្ម ថវិកា) ដើម្បីទទួលបានសម្ភារ សម្រាប់សាងសង់បង្គន់អនាម័យ |
| យោបល់ | • ប្រជាពលរដ្ឋនឹងទទួលបានផលប្រយោជន៍ពីការប្រតិបត្តិអនាម័យល្អ |

# ការផ្តល់វិញ្ញាបនបត្របច្ចេកទេសខួងអណ្តូង

| | |
|---|---|
| ឈ្មោះសេវា | ផ្តល់វិញ្ញាបនបត្របច្ចេកទេសខួងអណ្តូង |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងអភិវឌ្ឍន៍ជនបទ<br>• នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ<br>• អាសយដ្ឋាន : ភូមិព្រៃសាលា សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ<br>• ទូរស័ព្ទ: ៨៥៥-២៣ ៣៤៧ ៦៧៦<br>• ទូរសារ: ៨៥៥-២៣ ៣៤៧ ៦៧៦<br>• គេហទំព័រ : www.mrd.gov.kh |
| គោលបំណង<br>នៃការផ្តល់សេវា | • ក្រុមហ៊ុនឯកជនមានឱកាសចូលរួមផ្តល់សេវាផ្គត់ផ្គង់ទឹកប្រកបដោយគុណភាព និងស្របតាមបទដ្ឋានបច្ចេកទេសត្រឹមត្រូវ |
| មូលដ្ឋានគតិយុត្ត | • គោលការណ៍ និងបទដ្ឋានបច្ចេកទេសសាងសង់អណ្តូង |
| អតិថិជនដែលមាន<br>សិទ្ធិទទួលសេវា | • ក្រុមហ៊ុនឯកជនមានកម្រិត និងអង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធ |
| ស្តង់ដារសេវា | វិញ្ញាបនបត្រទទួលស្គាល់ដោយ ក្រសួងអភិវឌ្ឍន៍ជនបទមាន ០៣កម្រិត<br>• កម្រិតទី១ : សម្រាប់ប្រភេទខួងអណ្តូងដោយដៃ<br>• កម្រិតទី២ : សម្រាប់ប្រភេទខួងអណ្តូងដោយម៉ាស៊ីនកម្រិតម៉ាកពី ២០១<br>• កម្រិតទី៣ : សម្រាប់ប្រភេទខួងអណ្តូងដោយម៉ាស៊ីនកម្រិតម៉ាកចាប់ ពី ២០៣ ឡើង<br>• តម្លៃសេវា : (កំពុងរៀបចំជាប្រកាសអន្តរក្រសួង)<br>• សុពលភាព : រយៈពេល ០២ឆ្នាំ |
| តម្រូវការឯកសារ<br>ដើម្បីទទួលបានសេវា | • លិខិតស្នើសុំវិញ្ញាបនបត្រចំនួន០១ច្បាប់ មានជាប់ប័ណ្ណប៉ាតង់ អាជីវកម្ម<br>• បញ្ជីរាយប្រភេទឧបករណ៍ និងគ្រឿងចក្រ<br>• បំពេញបែបបទសំនួរបច្ចេកទេស |
| យោបល់ | • ពង្រីកលទ្ធភាពសេវាផ្គត់ផ្គង់ទឹកដោយមានការចូលរួមពីផ្នែកឯកជន |

# ការសាងសង់ និងជុសជុលអណ្តូងគ្រប់ប្រភេទ

| | |
|---|---|
| ឈ្មោះសេវា | ការសាងសង់ និងជុសជុលអណ្តូងគ្រប់ប្រភេទ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងអភិវឌ្ឍន៍ជនបទ<br>• នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ<br>• អាសយដ្ឋាន : ភូមិព្រៃសាលា សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ<br>• ទូរស័ព្ទ: (៨៥៥-២៣) ៣៤៧ ៦៧៦<br>• ទូរសារ: (៨៥៥-២៣) ៣៤៧ ៦៧៦<br>• សារអេឡិចត្រូនិច : maosaray@online.com.kh<br>• គេហទំព័រ : www.mrd.gov.kh |
| គោលបំណង នៃការផ្តល់សេវា | • ផ្តល់ទឹកស្អាតឱ្យបានគ្រប់គ្រាន់ប្រកបដោយគុណភាពដល់សហគមន៍ និង និរន្តភាព |
| មូលដ្ឋានគតិយុត្ត | • គោលការណ៍ និងបទដ្ឋានបច្ចេកទេសសេវាផ្គត់ផ្គង់ទឹកជនបទ |
| អតិថិជនដែលមាន សិទ្ធិទទួលសេវា | • ប្រជាពលរដ្ឋក្រីក្រនៅតាមសហគមន៍ជនបទ នៃព្រះរាជាណាចក្រកម្ពុជា |
| ស្តង់ដារសេវា | • ពី ១៥-៣៥ គ្រួសារទទួលបានអណ្តូង ០១ (ស្នប់ លូ ចម្រុះ)<br>• ទឹកអណ្តូងមានគុណភាព និងសុវត្ថិភាព<br>• រយៈពេលទទួលបាន : រយៈពេល ១០ ខែ ចាប់ពីពេលទទួលពាក្យ |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | • លិខិតស្នើសុំពីសហគមន៍មានបញ្ជីរាយឈ្មោះគ្រួសារប្រើប្រាស់ទីតាំងអណ្តូង ដែលត្រូវសាងសង់ ឬជុសជុល (នៅលើដីរបស់ឈ្មោះ...) និងមានបញ្ជាក់ពី ប្រធានគណៈកម្មាធិការអភិវឌ្ឍន៍ ភូមិ ប្រធាន ភូមិ មេឃុំ អភិបាលស្រុក និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត<br>• លិខិតដែលទាក់ទងទាំងអស់បញ្ជូនមកនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ នៃក្រសួង អភិវឌ្ឍន៍ជនបទ |
| យោបល់ | • ប្រជាពលរដ្ឋ និងទទួលបានទឹកស្អាតប្រើប្រាស់គ្រប់រដូវ<br>• កាត់បន្ថយជំងឺដង្កាត់ផ្សេងៗ ជាពិសេសក្មេងអាយុក្រោម ០៥ ឆ្នាំ<br>• កាត់បន្ថយភាពក្រីក្រ |

# ការវិភាគគុណភាពទឹក

| | |
|---|---|
| ឈ្មោះសេវា | ការវិភាគគុណភាពទឹក |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងអភិវឌ្ឍន៍ជនបទ<br>• នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ<br>• អាសយដ្ឋាន : ភូមិព្រៃសាលា សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ<br>• ទូរស័ព្ទ: (៨៥៥-២៣) ៣៥៥ ៣៥១<br>• ទូរសារ: (៨៥៥-២៣) ៣៥៥ ៣៥១<br>• សារអេឡិចត្រូនិច : maosaray@online.com.kh<br>• គេហទំព័រ : www.mrd.gov.kh |
| គោលបំណង នៃការផ្តល់សេវា | • ការពារសុវត្ថិភាពសុខុមាលភាពអ្នកប្រើប្រាស់ទឹក |
| មូលដ្ឋានគតិយុត្ត | • គោលការណ៍ និងបទដ្ឋានគុណភាពទឹក |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | • អ្នកប្រើប្រាស់ទូទៅ នៃព្រះរាជាណាចក្រកម្ពុជា |
| ស្តង់ដារសេវា | • កំរិតវិភាគ : ១៥ សារធាតុគីមីនៃសំណាកមួយ<br>• តម្លៃវិភាគ : កំពុងរៀបចំប្រកាសអន្តរក្រសួង<br>• លិខិតបញ្ជាក់លទ្ធផលវិភាគ : រយៈពេលពី២-៧ថ្ងៃ |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | • គម្រោងស្នើសុំ<br>• បញ្ជីឈ្មោះម្ចាស់អណ្តូង និងទីតាំងភូមិ លេខកូដអណ្តូង<br>• ទិន្នន័យអណ្តូង ដូចជា ជម្រៅ និងបរិមាណទឹក |
| យោបល់ | • អ្នកប្រើប្រាស់ និងទទួលបានទឹកដែលមានសុវត្ថិភាពល្អ |

# ការសាងសង់ ស្តារ និងជុសជុលប្រព័ន្ធធារាសាស្ត្រខ្នាតតូច

| | |
|---|---|
| ឈ្មោះសេវា | សាងសង់ ស្តារ និងជុសជុលប្រព័ន្ធធារាសាស្ត្រខ្នាតតូច |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងអភិវឌ្ឍន៍ជនបទ<br>• នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ<br>• អាសយដ្ឋាន : ភូមិព្រៃសាលា សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ<br>• ទូរស័ព្ទ: (៨៥៥-២៣) ៣៥៥ ៣៥១<br>• ទូរសារ: (៨៥៥-២៣) ៣៥៥ ៣៥១<br>• សារអេឡិចត្រូនិច : maosaray@online.com.kh<br>• សារអេឡិចត្រូនិច : keo_sek_kun@yahoo.com<br>• គេហទំព័រ : www.mrd.gov.kh |
| គោលបំណង នៃការផ្តល់សេវា | • ពង្រីកផ្ទៃដីដាំដុះ និងបង្កើនទិន្នផលកសិកម្មក្នុងតំបន់ជនបទ |
| មូលដ្ឋានគតិយុត្ត | • គោលការណ៍ និងបទដ្ឋានបច្ចេកទេសប្រព័ន្ធស្រោចស្រពខ្នាតតូច( ឆ្នាំ២00៣) |
| អតិថិជនដែលមាន សិទ្ធិទទួលសេវា | • ប្រជាកសិករនៅតាមសហគមន៍ជនបទដែលមានផ្ទៃដីបង្កបង្កើនផល |
| ស្តង់ដារសេវា | |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | • លិខិតស្នើសុំសហគមន៍<br>• រាល់សំណើត្រូវមានបញ្ជាក់ពីប្រធានគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ មេឃុំ អភិបាលស្រុក និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត<br>• របាយការណ៍វាយតម្លៃ បឋមរបស់មន្ត្រី នៃមន្ទីរអភិវឌ្ឍន៍ជនបទ រាជធានី ខេត្ត លើគម្រោងលទ្ធភាព និងតម្លៃប៉ាន់ស្មាន<br>• លិខិតទាំងអស់ត្រូវបញ្ជូនមកការិយាល័យប្រពន្ធ័ធារាសាស្ត្រខ្នាតតូចនៃ នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ |
| យោបល់ | ប្រជាកសិករមានលទ្ធភាពច្រើនថែមទៀតក្នុងការពង្រីងដីកសិកម្ម និង ទទួលបានទិន្នផលកើនឡើង |

# ផ្តល់មុខជំនាញវិជ្ជាជីវៈដល់ប្រជាពលរដ្ឋ នៅជនបទ

| | |
|---|---|
| ឈ្មោះសេវា | ផ្តល់មុខជំនាញវិជ្ជាជីវៈដល់ប្រជាពលរដ្ឋ នៅជនបទ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងអភិវឌ្ឍន៍ជនបទ<br>នាយកដ្ឋាន បណ្តុះបណ្តាល និង ស្រាវជ្រាវ<br>១-មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋាន ខេត្តស្វាយរៀង<br>• អាសយដ្ឋាន : ផ្លូវជាតិលេខ ១ ភូមិថ្នល់ ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង<br>• ទូរស័ព្ទ: ០១៦ ៦៩១ ១៤៨<br>• ទូរសារ: ០៤៤ ៩៤៥ ៧១៧<br>• គេហទំព័រ : www.mrd.com.kh<br>២-មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋាន ខេត្តព្រៃវែង<br>• អាសយដ្ឋាន :ភូមិ ៤ ឃុំកំពង់លាវ ស្រុកកំពង់លាវ ខេត្តព្រៃវែង<br>• ទូរស័ព្ទ: ០១២ ៨៩៩ ៥៦៧ . ០១២៧៧៣ ៨៣៦<br>៣- មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋាន ខេត្តតាកែវ<br>• អាសយដ្ឋាន: ផ្លូវជាតិលេខ ៣ ភូមិព្រៃញ៉ើក ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ<br>• ទូរស័ព្ទ: ០១៦ ៨៦៨ ៧៧៨ ០១៧ ២៥៨ ៧៧៨<br>• ទូរសារលេខ : ០៣២ ៩៣១ ២៦០<br>៤- មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋាន ខេត្តកំពង់ស្ពឺ<br>• អាសយដ្ឋាន : ភូមិចំការដូង ឃុំច្បារមន ស្រុកច្បារមន ខេត្តកំពង់ស្ពឺ<br>• ទូរស័ព្ទ: ០១២ ៩២៣ ៣៦៥<br>• ទូរសារ: ០២៥ ៩៨៧ ៣៣៧ |
| គោលបំណងនៃការផ្តល់សេវា | • ផ្តល់មុខជំនាញដល់ប្រជាពលរដ្ឋ ដើម្បីបង្កើតមុខរបរ |
| មូលដ្ឋានគតិយុត្ត | |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | • ប្រជាពលរដ្ឋទាំងពីរភេទ ដែលមានអាយុ ១៨ ឆ្នាំ ដល់ ៤០ ឆ្នាំ<br>• ចេះអាន និងចេះសរសេរភាសាខ្មែរ |
| ស្តង់ដារសេវា | • ការសិក្សាមានរយៈពេល ០៣-០៤ ខែ នៅក្នុងមជ្ឈមណ្ឌលដោយឥតគិតថ្លៃ |

| | |
|---|---|
| តម្រូវការឯកសារដើម្បីទទួលបានសេវា | • ពាក្យសុំចូលរៀន<br>• លិខិតបញ្ជាក់ទីលំនៅពីអាជ្ញាធរមូលដ្ឋាន<br>• បំពេញប្រវត្តិរូបនៅមជ្ឈមណ្ឌល |
| យោបល់ | • ការផ្ដល់សេវាបណ្ដុះបណ្ដាលមុខជំនាញមូលដ្ឋានដល់ប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់សមត្ថភាព ជំនាញសម្រាប់បង្កើតមុខរបរឱ្យពួកគាត់មានលទ្ធភាពរកប្រាក់ចំណូលបន្ថែម |

# សេវាសាងសង់ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ជនបទ

| | |
|---|---|
| ឈ្មោះសេវា | សេវាសាងសង់ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ជនបទ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងអភិវឌ្ឍន៍ជនបទ<br>• នាយកដ្ឋានផ្លូវលំជនបទ<br>• អាសយដ្ឋាន : កាច់ជ្រុងវិថីលេខលេខ ១៦៩ និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ<br>• ទូរស័ព្ទ : (៨៥៥-២៣) ៨៨១ ០៧៣<br>• ទូរសារ : (៨៥៥-២៣) ៨៨២ ០៧៣<br>• គេហទំព័រ : www.mrd.com.kh |
| គោលបំណងនៃការផ្តល់សេវា | • ស្តារ សាងសង់ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ស្ពាន លូ បម្រើឱ្យសេវាកម្មដឹកជញ្ជូនដល់ប្រជាពលរដ្ឋនៅតាមជនបទ |
| មូលដ្ឋានគតិយុត្ត | • គោលការណ៍ និងបទដ្ឋានបច្ចេកទេស |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | • ប្រជាពលរដ្ឋទូទៅ នៅតាមជនបទ នៃព្រះរាជាណាចក្រកម្ពុជា |
| ស្តង់ដារសេវា | |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | • លិខិតស្នើសុំពាក្យពីប្រធានគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ប្រធានភូមិ មេឃុំ អភិបាលស្រុក និងមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត<br>• លិខិតដែលទាក់ទងទាំងអស់ត្រូវបញ្ជូនមកក្រសួងអភិវឌ្ឍន៍ជនបទ |
| យោបល់ | |

# ក្រសួង  កិច្ចការនារី

អគារលេខ ៣ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ

ទូរស័ព្ទ : ០២៣ ៤២៨ ៩៦៥

ទូរសារ : (៨៥៥ ២៣) ៤២៨ ៩៦៥

អ៊ីម៉ែល : mwva@bigpond.com.kh

វិបសាយ : www.sspf.gov.kh

# កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី

| | |
|---|---|
| ឈ្មោះសេវា | កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងកិច្ចការនារី<br>• នាយកដ្ឋានការពារផ្លូវច្បាប់<br>• អាសយដ្ឋាន : ផ្លូវលេខ ៤៧ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>• ទូរស័ព្ទប្រធាននាយកដ្ឋាន : ០១២ ៤៣៣ ៦៨១<br>• ទូរស័ព្ទអនុប្រធាន : ០១១ ៧៤៩ ១៥៨ /០១២ ៩៩៦ ៤២៥<br>• ទូរស័ព្ទការិយាល័យ : ០២៣ ៤២៧ ៤៩៥<br>• អ៊ីម៉ែល : traksokundara@yahoo.com |
| គោលបំណងនៃការផ្តល់សេវា | • ដើម្បីធានាឱ្យស្ត្រី និងក្មេងស្រីទទួលបាននូវកិច្ចការពារផ្លូវច្បាប់ដោយស្មើភាព តាមរយៈការបញ្ចូលសិទ្ធិស្ត្រីចូលក្នុងដំណើរការតាក់តែងរៀបចំ និងអនុវត្តច្បាប់ និងផ្តល់សេវាដល់ជនរងគ្រោះដោយអំពើហិង្សា និងការជួញដូរមនុស្សដោយមានប្រសិទ្ធភាព<br>• លើកកម្ពស់កិច្ចការពារផ្លូវច្បាប់ប្រឆាំងរាល់ទម្រង់នៃការរើសអើងលើស្ត្រី និងកុមារ រួមទាំងអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ អំពើអាសអាភាស អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទ កម្លាំងពលកម្ម និងទេសន្តរប្រវេសន៍<br>• បង្កើនប្រសិទ្ធភាពក្នុងការទទួលបាននូវសេវាការពារផ្លូវច្បាប់ដល់ស្ត្រី ដែលរងគ្រោះដោយអំពើហិង្សា និងអំពើជួញដូរមនុស្ស<br>• បង្កើនការទទួលបាន និងផ្តល់សេវាសង្គម និងសុខាភិបាលដល់ជនរងគ្រោះដោយអំពើហិង្សា រួមទាំងអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្ម |
| មូលដ្ឋានគតិយុត្ត | • ព្រះរាជក្រមលេខ នស/រកម/១០០៥/០៣១ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៥ ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ<br>• ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី៣០ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ |

| | |
|---|---|
| | • ប្រកាសអន្តរក្រសួងលេខ ៦៤ ប្រកកយ កកន/០៧ ចុះថ្ងៃ៣០ ខែតុលា ឆ្នាំ ២០០៧ ស្តីពីការតែងតាំងនគរបាលយុត្តិធម៌របស់ក្រសួងកិច្ចការនារី ឆ្នាំ ២០០៧ |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | |
| ស្តង់ដារសេវា | |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | |
| យោបល់ | • ផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ដល់ជនរងគ្រោះអំពើហិង្សាក្នុងគ្រួសារ និងការជួញដូរ គ្រប់ម៉ោងធ្វើការ |

# ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី

| | |
|---|---|
| ឈ្មោះសេវា | ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងកិច្ចការនារី<br>• នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច<br>• អាសយដ្ឋាន : ផ្លូវលេខ ៤៧ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>• ទូរស័ព្ទប្រធាននាយកដ្ឋាន : ០១២ ៧៥៥ ១៩៦<br>• ទូរស័ព្ទអនុប្រធាន : ០១១ ៧៤៧ ០៦៥ /០១៦ ៦៩១ ១៦៧<br>• ទូរស័ព្ទការិយាល័យ : ០២៣ ៤២៦ ៩៨០<br>• អ៊ីមែល : veasna.adbjfpr@online.com.kh |
| គោលបំណងនៃការផ្តល់សេវា | • លើកកម្ពស់ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចរបស់ស្ត្រីតាមរយៈការជំរុញឱ្យមានគោលនយោបាយឆ្លើយតបយេនឌ័រក្នុងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចដល់ស្ត្រី ពិសេសស្ត្រីក្រីក្រ ស្ត្រីពិការ និងស្ត្រី វ័យក្មេងដែលពុំមានការងារធ្វើ និងស្ត្រីរងគ្រោះ<br>• លើកកម្ពស់ឱកាសការងារសម្រាប់ស្ត្រី ដោយរួមទាំងការប្រកបមុខរបរក្រៅប្រព័ន្ធ ពង្រឹងសេវាអភិវឌ្ឍន៍ជំនួញ ដើម្បីបង្កើនលទ្ធភាពសហគ្រាសខ្នាតមីក្រូតូច និងមធ្យមរបស់ស្ត្រី |
| មូលដ្ឋានគតិយុត្ត | • ប្រកាសលេខ ០៩៥ កកន/ប្រក ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៧ ស្តីពី ការបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍស្ត្រី ខេត្ត ក្រុង |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | |
| ស្តង់ដារសេវា | |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | |
| យោបល់ | |

# ក្រសួងសង្គមកិច្ច  អតីតយុទ្ធជន  និងយុវនីតិសម្បទា

អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ

ទូរស័ព្ទ , ទូរសារ : (៨៥) ២៣.៧២៦០៨៦

# របបឧបត្ថម្ភគោលនយោបាយចំពោះជនពិការស្នាក់នៅ
# ក្នុងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា

| | |
|---|---|
| ឈ្មោះសេវា | របបឧបត្ថម្ភគោលនយោបាយចំពោះជនពិការស្នាក់នៅក្នុងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទារបស់រដ្ឋ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>អគ្គនាយកដ្ឋានបច្ចេកទេស<br>នាយកដ្ឋានស្តារលទ្ធភាពពលកម្ម<br>ការិយាល័យបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ<br>អាសយដ្ឋានមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា រាជធានី ខេត្ត |
| គោលបំណងនៃការផ្តល់សេវា | • ដើម្បីទទួលសេវាស្តារលទ្ធភាពពលកម្មកាយសម្បទា (ជើងសិប្បនិម្មិត និងរណបឧបករណ៍ទ្រទ្រង់រាងកាយ រទេះរុញ និងការព្យាបាលដោយចលនា)<br>• បង្កលក្ខណៈងាយស្រួលដល់ជនពិការ ដែលមកទទួលសេវាស្តារលទ្ធភាពពលកម្មកាយសម្បទារបស់រដ្ឋ |
| មូលដ្ឋានគតិយុត្ត | • អនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរដ្ឋ<br>• សារាចរណែនាំលេខ ០០៤ ស.អ.យ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការអនុវត្តអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពី របបគោលនយោបាយ ចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | • ជនពិការស្នាក់នៅក្នុងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទារបស់រដ្ឋ |
| ស្តង់ដារសេវា | • ជនពិការ ១នាក់ ទទួលបានរបបឧបត្ថម្ភសម្រាប់ម្ហូបអាហារចំនួន ៤៥.០០០រៀល ក្នុងមួយខែ ជនពិការ ១នាក់ ទទួលបានរបបឧបត្ថម្ភ សម្រាប់សម្លៀកបំពាក់ សម្ភារសិក្សា កីឡា សម្ភារដំណេក ផ្ទះបាយ អនាម័យ និងព្យាបាលចំនួន ១២០ ០០០ រៀល ក្នុងមួយឆ្នាំ<br>• ជនពិការ ១នាក់ ទទួលបានរបបឧបត្ថម្ភសម្រាប់បណ្តុះបណ្តាលមុខជំនាញ |

| | |
|---|---|
| | វិជ្ជាជីវៈ ចំនួន ៣៩០ ០០០រៀល ក្នុង ១វគ្គ ដែលមានរយៈពេលខ្លី ០៣ខែ<br>• ជនពិការបាត់បង់សមត្ថភាពពលកម្មធ្ងន់ធ្ងរ និងជនពិការមានជម្ងឺអេដស៍ ១នាក់ ទទួលបានរបបឧបត្ថម្ភសម្រាប់បំប៉នសុខភាពចំនួន ២០ ០០០ រៀល ក្នុង ១ខែ<br>• ជនពិការទទួលមរណភាពទទួលបានប្រាក់ឧបត្ថម្ភសម្រាប់រៀបចំពិធីបុណ្យសព ចំនួន ៥៤០.០០០ រៀល<br>• ជនពិការធ្វើសមាហរណកម្មត្រូវបានទទួលរបបឧបត្ថម្ភចំនួន ៨១០.០០០ រៀល |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | • សំណើរបស់ប្រធានមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា និងប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត<br>• សេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ សម្បទា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| យោបល់ | |

# របបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ

| | |
|---|---|
| ឈ្មោះសេវា | របបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• អគ្គនាយកដ្ឋានបច្ចេកទេស<br>• នាយកដ្ឋានសុខុមាលភាពកុមារ<br>• ការិយាល័យគ្រប់គ្រងកុមារកំព្រា<br>• អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ សង្កាត់បឹងត្របែក ខណ្ឌចំការមន |
| គោលបំណងនៃការផ្តល់សេវា | • ការផ្តល់សេវាស្នាក់នៅ ហូបចុក ស្លៀកពាក់ដល់ទារក/កុមារ ដែលរស់នៅក្នុងមជ្ឈមណ្ឌលកុមារកំព្រារបស់រដ្ឋ មានដូចជាទារកកំព្រា កុមារកំព្រា ទារក/កុមារស្ថិតនៅគ្រួសារទីទាល់ក្រ ទារក/កុមារត្រូវគេបោះបង់ចោល កុមារពិការ កុមាររងផលប៉ះពាល់ ឬផ្ទុកមេរោគអេដស៍ ឬមានជំងឺអេដស៍ កុមារអនាថា កុមាររងផលប៉ះពាល់ដោយសារអំពើហិង្សាក្នុងគ្រួសារ កុមារត្រូវបានរំលោភបំពាន កុមារត្រូវបានកេងប្រវ័ញ្ច<br>• ធ្វើឱ្យប្រសើរឡើងនូវផ្នែកជីវភាពរបស់មុខសញ្ញាខាងលើ ដើម្បីទទួលបានការចិញ្ចឹមបីបាច់ថែទាំ ស្តារលទ្ធភាពពលកម្ម ផ្គត់ផ្គង់ជីវភាព អប់រំបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងត្រូវបានធ្វើសមាហរណកម្មទៅក្នុងសហគមន៍ |
| មូលដ្ឋានគតិយុត្ត | អនុសញ្ញាស្តីពីសិទ្ធិកុមារ :<br>• ច្បាប់ស្តីពី កិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ<br>• អនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅមជ្ឈមណ្ឌលរដ្ឋ<br>• ប្រកាសលេខ ៣៥៩ ស.អ.យ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០០៦ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត-រាជធានី<br>• គោលនយោបាយស្តីពី ការថែទាំជំនួសចំពោះកុមារ<br>• បទដ្ឋានអប្បបរមាស្តីពី ការថែទាំជំនួសចំពោះកុមារ<br>• សារាចរណែនាំលេខ ០០៤ ស.អ.យ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពី |

| | |
|---|---|
| | ការអនុវត្តអនុក្រឹត្យ លេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០០៦ |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | • ទារក/កុមារដែលរស់នៅក្នុងមជ្ឈមណ្ឌលកុមារកំព្រារបស់រដ្ឋ មានដូចជា ទារកកំព្រា កុមារកំព្រា ទារក/កុមារស្ថិតនៅគ្រួសារទីទាល់ក្រ ទារក/កុមារត្រូវគេបោះបង់ចោល កុមារពិការ កុមាររងផលប៉ះពាល់ ឬផ្ទុកមេរោគអេដស៍ ឬមានជំងឺអេដស៍ កុមារអនាថា កុមាររងផលប៉ះពាល់ដោយសារអំពើហិង្សាក្នុងគ្រួសារ កុមារត្រូវបានរំលោភបំពាន កុមារត្រូវបានកេងប្រវ័ញ្ច |
| ស្តង់ដារសេវា | • ទារកក្រោម ២ឆ្នាំ ចុះទទួលបានរបបទឹកដោះគោ ៦០ ០០០រៀល ក្នុង ១ខែ ក្នុង ១នាក់<br>• កុមារអាយុលើស ២ឆ្នាំទទួលបានរបបម្ហូបអាហារ ៤៥ ០០០ រៀល ក្នុង ១ខែ ក្នុង ១នាក់<br>• ទារក/កុមារពិការធ្ងន់ធ្ងរមានជំងឺរ៉ាំរ៉ៃ ផ្ទុកមេរោគអេដស៍ ឬមានជំងឺអេដស៍ ទទួលបាន ២០ ០០០រៀល ក្នុង១ខែ ក្នុង១នាក់ សម្រាប់ប្រាក់បំប៉នសុខភាពបន្ថែមលើប្រាក់ម្ហូប<br>• ទទួលបានប្រាក់សម្រាប់សម្លៀកបំពាក់សម្ភារសិក្សា កីឡា សម្ភារដំណេក ផ្ទះបាយ អនាម័យ និងព្យាបាល ១២០ ០០០ រៀល ក្នុង ១ខែ ក្នុង ១នាក់<br>• ទារក/កុមារអាយុ៥ឆ្នាំចុះ ទទួលមរណភាព ទទួលបានប្រាក់សម្រាប់រៀបចំពិធីបុណ្យសព ២៧០ ០០០ រៀល ស្មើប្រាក់ម្ហូបអាហារ ៦ខែ ក្នុង ១នាក់<br>• កុមារអាយុលើសពី ៥ឆ្នាំ ទទួលមរណភាពទទួលបានប្រាក់សម្រាប់រៀបចំពិធីបុណ្យសព ៥៤០ ០០០ រៀល ស្មើប្រាក់ម្ហូបអាហារ ១២ខែ ក្នុង ១នាក់<br>• កុមារ យុវកុមារអាយុពី ៧ ដល់ក្រោម ១៨ឆ្នាំ ទទួលបានការបណ្តុះបណ្តាលមុខវិជ្ជាជីវៈ ១វគ្គ រយៈពេលខ្លី ៣ខែ ៣៩០ ០០០ រៀល ក្នុង ១នាក់<br>• អាយុ ១៨ឆ្នាំ ឡើងទទួលបានការធ្វើសមាហរណកម្ម១ដងគត់ ១ ០៨០ ០០០ រៀល ស្មើប្រាក់ម្ហូបអាហារ ២៤ខែ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | • ប្រកាសបញ្ចូលឈ្មោះកុមារទៅក្នុងមជ្ឈមណ្ឌលរដ្ឋ<br>• ប្រកាសបញ្ចេញឈ្មោះកុមារពីមជ្ឈមណ្ឌលរដ្ឋ<br>• ប្រកាសលុបឈ្មោះកុមារដែលត្រូវស្លាប់ពីមជ្ឈមណ្ឌលរដ្ឋ |
| យោបល់ | |

# របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
# និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក

| | |
|---|---|
| ឈ្មោះសេវា | ការផ្តល់របបសន្តិសុខសង្គមជូនមន្ត្រីរាជការស៊ីវិល និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលមានស្ថានភាពចូលនិវត្តន៍ បាត់បង់សម្បទាវិជ្ជាជីវៈ មាតុភាព គ្រោះថ្នាក់ការងារ និងមរណភាព និងអ្នកនៅក្នុងបន្ទុក នៃជនទាំងនេះ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ស្ថិតនៅក្រោមអាណាព្យាបាលផ្នែកបច្ចេកទេសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងស្ថិតនៅក្រោមអាណាព្យាបាលផ្នែកហិរញ្ញវត្ថុរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>• អាសយដ្ឋាន : នៅក្នុងទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ<br>• ទូរស័ព្ទ : (៨៥៥)២៣ ៩៨៧ ៥១២<br>• ទូរសារ : (៨៥៥)២៣ ៩៨៧ ៥១២ |
| គោលបំណង<br>នៃការផ្តល់សេវា | • ការផ្តល់របបសន្តិសុខសង្គមជូនមន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុកតាមគោលការណ៍ អភិបាលកិច្ចល្អ មានតម្លាភាព ប្រសិទ្ធភាព និងមានការទទួលខុសត្រូវខ្ពស់ ។ |
| មូលដ្ឋានគតិយុត្ត | • ព្រះរាជក្រឹត្យ នស/រកត/០១០៨/០៣៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ ស្តីពី របបសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល<br>• អនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពី ការបង្កើតបេឡាជាតិសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល<br>• ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា<br>• អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១០ ស្តីពី ការកែសម្រួល ការអនុវត្តបើកប្រាក់សោធនចំពោះមន្ត្រីរាជការ ដែលជានិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារ ជនពិការ និងគ្រួសារជនពលី គ្រួសារជនមរណៈដែលទទួលមុខតំណែងជាអ្នកនយោបាយ |

| | |
|---|---|
| | • អនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៩ ស្តីពីការផ្តល់ប្រាក់បំណាច់ជីវភាពជូនមន្ត្រីរាជការស៊ីវិល កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យុទ្ធជនពិការ និងអតីតយុទ្ធជន<br>• អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកែប្រែតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សរ៍មូលដ្ឋាន របស់មន្ត្រីរាជការស៊ីវិល<br>• អនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៨ ស្តីពីការតម្លើងប្រាក់ឧបត្ថម្ភប្រចាំខែជូនប្រពន្ធ ប្តី និងកូនរបស់មន្ត្រីបាត់បង់សមត្ថភាពពលកម្ម និងយុទ្ធជនពិការ<br>• អនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០២ ស្តីពីការកែសម្រួលការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទា-វិជ្ជាជីវៈ ជូនមន្ត្រីរាជការស៊ីវិលតាមប្រព័ន្ធបៀវត្សថ្មី<br>• អនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្ត និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា<br>• សេចក្តីសម្រេចលេខ ៥២ សសរ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពី ការកែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយធានារ៉ាប់រងសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល<br>• សេចក្តីសម្រេចលេខ ២៤៥ សសរ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពី របបគោលនយោបាយធានារ៉ាប់រងសង្គម សម្រាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និវត្តជន និងជនបាត់បង់ សមត្ថភាពពលកម្ម<br>• សារាចរណែនាំ លេខ ០១១ ស.អ.យ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពី ការបើកប្រាក់សោធនចំពោះមន្ត្រីរាជការដែលជានិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារ ជនពិការ និងគ្រួសារ ជនពលី គ្រួសារជនមរណៈ ដែលទទួលមុខតំណែងជាអ្នកនយោបាយ<br>• សារាចរលេខ ០០៦ ស.អ.យ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពី ការផ្តល់ប្រាក់បំណាច់ជីវភាពជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ<br>• សេចក្តីណែនាំលេខ ០០៣ ស.អ.យ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ |

| | |
|---|---|
| | របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្ដីពី ការពង្រឹងការអនុវត្តរបបសោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ<br>• សារាចរណែនាំលេខ ០០៤ សរណន.សអយ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០០៨ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្ដីពី ការតម្លើងប្រាក់ឧបត្ថម្ភប្រចាំខែជូនប្រពន្ធ ប្ដី និងកូនកំព្រារបស់និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ សពនិវត្តជន សពជនបាត់បង់សម្បទាវិជ្ជាជីវៈ និងសពមន្ត្រីរាជការស៊ីវិល<br>• សារាចរណែនាំលេខ ០០២ សរណន.សអយ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ ២០០៦ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្ដីពី ការកែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយធានារ៉ាប់រងសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល<br>• សារាចរណែនាំអនុវត្តលេខ ៣៣ យ.ស.សរណន ចុះថ្ងៃទី១១ ខែមករា ឆ្នាំ១៩៨៩ របស់ក្រសួងយុទ្ធជនពិការ សង្គមកិច្ច លើសេចក្ដីសម្រេច ២៤៥ សសរ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្ដីពី របបគោលនយោបាយធានារ៉ាប់រងសង្គម សម្រាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និវត្តជន និងជនបាត់បង់សមត្ថភាពពលកម្ម |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | • មន្ត្រីរាជការស៊ីវិល (រួមមានចៅក្រម និងព្រះរាជអាជ្ញា) និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ (រួមមានអ្នកចូលនិវត្តន៍ដែលកំពុងទទួលមុខតំណែងជាអ្នកនយោបាយ) និងអ្នកនៅក្នុងបន្ទុក នៃជនទាំងនេះ |
| ស្តង់ដារសេវា | មន្ត្រីរាជការស៊ីវិល និងអ្នកនៅក្នុងបន្ទុក<br>• មន្ត្រីរាជការទទួលមរណភាពដោយជំងឺ ប្រាក់ឧបត្ថម្ភជូនគ្រួសារសព ចំនួន ០៦ខែ និងប្រាក់បូជាសពចំនួន ១ ២០០ ០០០រៀល ព្រមទាំងផ្ដល់ប្រាក់-ឧបត្ថម្ភប្រចាំខែជូនកូនម្នាក់ ៥.០០០រៀល រហូតដល់អាយុ២១ ឆ្នាំ (អាយុពី ១៥ ឆ្នាំ រហូតដល់ ២១ ឆ្នាំ ត្រូវភ្ជាប់មកជាមួយលិខិតបញ្ជាក់ការសិក្សា)<br>• មន្ត្រីរាជការទទួលមរណភាពដោយគ្រោះថ្នាក់ការងារ ឬបេសកកម្មប្រាក់-ឧបត្ថម្ភជូនគ្រួសារសពចំនួន ៨ខែ និងប្រាក់បូជាសពចំនួន ១៥០០ ០០០រៀល ព្រមទាំងផ្ដល់ប្រាក់ឧបត្ថម្ភប្រចាំខែ ជូនកូនម្នាក់ ៥ ០០០ រៀល រហូតដល់ អាយុ ២១ឆ្នាំ (អាយុពី១៥ឆ្នាំ រហូតដល់ ២១ឆ្នាំ ត្រូវភ្ជាប់មកជាមួយ លិខិតបញ្ជាក់ការសិក្សា)<br>• លំហែមាតុភាព ៦០០ ០០០រៀល និងកូនភ្លោះទ្វេជាពីរ |

| | |
|---|---|
| | • ផ្តល់គោលការណ៍ទៅក្រសួង ស្ថាប័ននានា ក្នុងការផ្តល់ប្រាក់ឧបត្ថម្ភជូនមន្ត្រីរាជការចូលនិវត្តន៍ ឬបាត់បង់សម្បទាវិជ្ជាជីវៈមួយលើកដំបូង<br><br>ចំពោះមន្ត្រីរាជការដែលចូលនិវត្តន៍<br>ប្រាក់ឧបត្ថម្ភមួយលើកដំបូង = បៀវត្សមូលដ្ឋាន x ៨ខែ<br>ប្រាក់សោធនប្រចាំខែ = បៀវត្សមូលដ្ឋាន x អតីតភាពការងារ (៨០% អតីតភាពការងារអតិបរមា ៣០ឆ្នាំ និង ៦០% អតីតភាពការងារអប្បបរមា ២០ឆ្នាំ)<br><br>ចំពោះមន្ត្រីរាជការដែលចូលបាត់បង់សម្បទាវិជ្ជាជីវៈ<br>ប្រាក់ឧបត្ថម្ភមួយលើកដំបូង = បៀវត្សមូលដ្ឋាន x ៧ខែ<br>ប្រាក់សោធនប្រចាំខែ = បៀវត្សមូលដ្ឋាន x អតីតភាពការងារ (៦៥% អតីតភាពការងារអតិបរមា ២៩ឆ្នាំ និង ៥០% អតីតភាពការងារអប្បបរមា ២០ឆ្នាំ)<br><br>និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក<br>• និវត្តជនប្រាក់សោធនអតិបរមា ៣៧៩ ៣២០ រៀល អប្បបរមា ៨៧ ០០០ រៀល ជនបាត់បង់សម្បទាវិជ្ជាជីវៈប្រាក់សោធនអតិបរមា ៣៤១ ៣៨៨ រៀល អប្បរមា ៧៨ ៣០០រៀល<br>• និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ទទួលមរណភាព ប្រាក់សោធនសរុបចំនួន ១២ ខែ<br>• ប្រាក់ឧបត្ថម្ភសហព័ទ្ធ ៦ ០០០រៀល និងកូនម្នាក់ ៥.០០០រៀល រហូតដល់អាយុ ២១ឆ្នាំ (អាយុពី១៥ឆ្នាំ រហូតដល់ ២១ឆ្នាំ ត្រូវភ្ជាប់មកជាមួយលិខិតបញ្ជាក់ការសិក្សា) |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | ការទទួលបានប្រាក់ឧបត្ថម្ភដល់គ្រួសារសពមន្ត្រីរាជការស៊ីវិល ដែលទទួលមរណភាពដោយជំងឺ<br>• លិខិតស្នើសុំប្រាក់ឧបត្ថម្ភប្រចាំខែកូនកំព្រាពីក្រសួងស្ថាប័ន ០២ច្បាប់<br>• លិខិតបញ្ជាក់ការសិក្សារបស់កូន (ម្នាក់ៗ) ០១ ច្បាប់<br>• ប្រកាសលុបឈ្មោះសពមន្ត្រីរាជការស៊ីវិល ០១ ច្បាប់<br>• សេចក្តីចម្លងសំបុត្របញ្ជាក់មរណភាពពីអាជ្ញាធរមូលដ្ឋាន ០១ ច្បាប់<br>• តារាងរៀបរាប់ស្ថានភាពគ្រួសារសព ០១ ច្បាប់ |

| | |
|---|---|
| | • វិញ្ញាបនបត្រផ្ដាច់ប្រាក់បៀវត្សរ៍របស់សព ០២ ច្បាប់<br>• តារាងទូទាត់ប្រាក់ធានារ៉ាប់រងសង្គម ០២ ច្បាប់<br>• សេចក្ដីសម្រេចរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ០១ ច្បាប់<br><br>ការទទួលបានប្រាក់ឧបត្ថម្ភដល់គ្រួសារសពមន្ត្រីរាជការស៊ីវិល ដែលទទួលមរណភាពដោយគ្រោះថ្នាក់ការងារ និងបេសកកម្ម<br>• លិខិតស្នើសុំប្រាក់ឧបត្ថម្ភប្រចាំខែកូនកំព្រាពីក្រសួងស្ថាប័ន ០២ច្បាប់<br>• លិខិតបញ្ជាក់ការសិក្សារបស់កូន (ម្នាក់ៗ) ០១ ច្បាប់<br>• ប្រកាសលុបឈ្មោះសពមន្ត្រីរាជការស៊ីវិល ០១ ច្បាប់<br>• លិខិតមរណភាព ០១ ច្បាប់<br>• លិខិតបញ្ជាបេសកកម្ម ឬ លិខិតឧទ្ទេសនាម ០១ ច្បាប់<br>• កំណត់ហេតុគ្រោះថ្នាក់ការងារ ឬពេលបំពេញបេសកកម្ម របស់អង្គភាពមានសមត្ថកិច្ច ០១ ច្បាប់<br>• តារាងរៀបរាប់ស្ថានភាពគ្រួសារសព ០១ ច្បាប់<br>• វិញ្ញាបនបត្រផ្ដាច់ប្រាក់បៀវត្សរ៍របស់សព ០២ ច្បាប់<br>• តារាងទូទាត់ប្រាក់ធានារ៉ាប់រងសង្គម ០២ ច្បាប់<br>• សេចក្ដីសម្រេចរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ០១ ច្បាប់<br><br>ការទទួលបានប្រាក់ឧបត្ថម្ភ របស់មន្ត្រីរាជការស៊ីវិល ពេលលំហែមាតុភាព (បច្ចុប្បន្នក្រសួង ស្ថាប័នសាមីជាអ្នកអនុវត្ត)<br>• លិខិតស្នើសុំប្រាក់ឧបត្ថម្ភគោលនយោបាយធានារ៉ាប់រងសង្គម ០១ ច្បាប់<br>• លិខិតបញ្ជាក់ថាបានសំរាលកូនចេញពីមន្ទីរពេទ្យ ឬពីអង្គភាព ដែលគ្រប់គ្រងសាមីជន ០១ ច្បាប់<br>• សេចក្ដីចម្លងសំបុត្របញ្ជាក់កំណើតកូនពីអាជ្ញាធរមូលដ្ឋាន ០១ ច្បាប់<br><br>ការចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈរបស់មន្ត្រីរាជការស៊ីវិល<br>• ពាក្យស្នើសុំចេញសៀវភៅនិវត្តជន ឬជនបាត់បង់សម្បទាវិជ្ជាជីវៈ ០១ ច្បាប់<br>• ប្រកាសឱ្យចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ (ច្បាប់ដើម១) ០២ ច្បាប់ |

| | |
|---|---|
| | • លិខិតបញ្ជាក់អំពីរយៈពេលបំពេញការងាររបស់អ្នករាជការ ០២ច្បាប់<br>• ជីវប្រវត្តិរូបសង្ខេបរបស់សាមីជន ០២ ច្បាប់<br>• ពាក្យសុំចូលនិវត្តន៍របស់អ្នករាជការដែលមានអតីតភាពការងារ ៣០ឆ្នាំ ឡើងទៅមិនទាន់គ្រប់អាយុ ហើយស្ម័គ្រចិត្តចូលនិវត្តន៍ ០១ ច្បាប់<br>• សេចក្តីសំរេចឱ្យបន្តការងារមួយឆ្នាំម្តងៗ បើអ្នករាជការនោះមានអាយុលើសពី ៥៥ ឆ្នាំឡើង ០១ ច្បាប់<br>• លិខិតបញ្ជាក់ការងារប៉ះពាល់សុខភាព បើអ្នករាជការនោះធ្វើការនៅកន្លែងប៉ះពាល់សុខភាព ០១ ច្បាប់<br>• វិញ្ញាបនបត្របញ្ជាក់បាត់បង់សម្បទាវិជ្ជាជីវៈចេញដោយគណៈកម្មការវាយតម្លៃសុខភាព បើអ្នករាជការនោះបាត់បង់សម្បទាវិជ្ជាជីវៈ ០១ ច្បាប់<br>• កំណត់ហេតុស្តីពីគ្រោះថ្នាក់ការងារ ឬបេសកកម្ម បើអ្នករាជការនោះទទួលគ្រោះថ្នាក់ដោយបំពេញការងារ ០១ ច្បាប់<br>• រូបថត ៤ គុណ ៦ ០៣ សន្លឹក<br>• រូបថត ៣ គុណ ៤ ០១ សន្លឹក<br><br>ការទទួលបានប្រាក់ឧបត្ថម្ភ ដល់គ្រួសារសពនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ និងបន្តការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនអ្នកនៅក្នុងបន្ទុក<br>• សំណើសុំលុបឈ្មោះនិវត្តជន ឬជនបាត់បង់សម្បទាវិជ្ជាជីវៈ<br>• សំណើសុំប្រាក់ធានារ៉ាប់រងសង្គម<br>• តារាងរៀបរាប់ស្ថានភាពគ្រួសារសព<br>• សេចក្តីចម្លងសំបុត្រមរណភាព<br>• ពាក្យសុំប្រាក់ធានារ៉ាប់រងសង្គម<br>• សៀវភៅនិវត្តជន ឬជនបាត់បង់សម្បទាវិជ្ជាជីវៈ<br>• វិញ្ញាបនបត្រផ្តាច់ប្រាក់សោធននិវត្តន៍ ឬសោធនបាត់បង់សម្បទាវិជ្ជាជីវៈ |
| យោបល់ | ក្រោយពីអ្នកស្នើសុំបានបំពេញលក្ខខណ្ឌ ដែលបានកំណត់តាមគោលការណ៍ ដូចមានចែងក្នុងចំណុច "តម្រូវការឯកសារដើម្បីទទួលបានសេវា" រួចហើយ បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលនឹងផ្តល់សេវា ជូនតាមគោលការណ៍អភិបាលកិច្ចល្អ មានតម្លាភាព ប្រសិទ្ធភាព និងមានការទទួលខុសត្រូវខ្ពស់។ នាពេលអនាគត បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលនឹងពង្រីកសេវាបន្ថែមទៀត ដើម្បីជួយកាត់បន្ថយការលំបាករបស់មុខសញ្ញា |

# កម្មវិធីជំនួយសង្គ្រោះប្រជាជនរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតុ

| | |
|---|---|
| ឈ្មោះសេវា | កម្មវិធីជំនួយសង្គ្រោះប្រជាជនរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតុ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងសង្គមកិច្ចនិងអតីតយុទ្ធជន និងយុវនីតិសម្បទា<br>• អគ្គនាយកដ្ឋានបច្ចេកទេស<br>• នាយកដ្ឋានសុខុមាលភាពសង្គម<br>• ការិយាល័យ សង្គ្រោះសង្គម<br>• អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ |
| គោលបំណងនៃការផ្តល់សេវា | • កម្មវិធីជួយសង្គ្រោះប្រជាជនដាច់ស្បៀង ទីទ័លក្រ រងគ្រោះដោយធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតុផ្សេងៗ ជាសេវាកម្មសាធារណៈរបស់ក្រសួង ស.អ.យ ត្រូវបានបង្កើតឡើងក្នុងគោលបំណងអនុវត្តគោលនយោបាយ របស់រាជរដ្ឋាភិបាលក្នុងការជួយសម្រាលទុក្ខលំបាកក្នុងជីវភាពរស់នៅចាំបាច់របស់ប្រជាជនរងគ្រោះនៅតាមមូលដ្ឋាន និងសហគមន៍ |
| មូលដ្ឋានគតិយុត្ត | • សារាចរណែនាំ លេខ ០០៦ ស.អ.យ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៦ ស្តីពី កម្មវិធីជំនួយសង្គ្រោះប្រជាជនរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតុដោយមានភ្ជាប់គំរូឧបសម្ព័ន្ធ លេខ ០១ ដល់លេខ ០៧ |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | • ប្រជាជន ជាជនងាយរងគ្រោះ ដាច់ស្បៀង ទីទ័លក្រ រងគ្រោះធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតុផ្សេងៗ |
| ស្តង់ដារសេវា | ប្រជាជនជាជនងាយរងគ្រោះ ដាច់ស្បៀង ទីទ័លក្រ រងគ្រោះដោយធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតុផ្សេងៗ ត្រូវបានជួយសង្គ្រោះតាមប្រភេទ និងកំរិតដូចខាងក្រោម :<br>• ប្រជាជនរងគ្រោះទីទ័លក្រ ដាច់ស្បៀងជាស្ថាពរគ្មានមុខរបរគ្មានដីធ្លីដាំដុះគ្មានជម្រកស្នាក់នៅ ឬមេគ្រួសារជាស្ត្រីមេម៉ាយមានកូនច្រើនក្នុងបន្ទុកពុំមានលទ្ធភាពឱ្យកូនទៅសិក្សា ឬមេគ្រួសារជាជនពិការ ជនចាស់ជរា |

| | |
|---|---|
| | ជនមានជំងឺរ៉ាំរ៉ៃ ហើយមានក្មេងក្នុងបន្ទុកពុំមានលទ្ធភាពឱ្យក្មេងទៅសិក្សា ត្រូវពិនិត្យលទ្ធភាពផ្តល់ជំនួយគាំទ្រ ដោយគិតចំនួនសមាជិកគ្រួសារតាមជំហានដូចខាងក្រោម :<br>- ជំហានទី ១ : ត្រូវផ្តល់ជំនួយសង្គ្រោះបន្ទាន់ ជាសម្ភារប្រើប្រាស់ និងស្បៀងអាហារដោយគិតជាថវិកាមិនលើសពី ៣០០ ០០០រៀល ឡើយ ក្នុងមួយគ្រួសារ ដូចជា អង្ករ ៥០គ.ក្រ អំបិល ៥គ.ក្រ មី ១កេសតូច មុងខ្នាតធំ១ កន្ទេលនីឡុងធំ ១ និងភួយ១<br>- ជំហានទី ២ : ត្រូវផ្តល់ជំនួយគាំទ្រសម្រាប់ការស្តារនីតិសម្បទា ដើម្បីឱ្យប្រជាជនរងគ្រោះមានស្ថេរភាពស្បៀង សម្រាប់ជីវភាពប្រចាំថ្ងៃ ក្នុងរយៈពេល ៣០ថ្ងៃ ឬអាចបន្តរយៈពេល ២ដង ប្រសិនបើចាំបាច់ និងរួមចំណែកលើកទឹកចិត្ត ផ្តល់សម្ភារសម្រាប់ជួសជុលផ្ទះសម្បែង ឬសាងសង់ជម្រកស្នាក់នៅដោយគិតជាថវិកាមិនលើសពី ១៥០ ០០០ រៀល ក្នុងមួយគ្រួសារ ១នាក់ទទួលបានអង្ករ ១០ គ.ក្រ<br>• ប្រជាជនរងគ្រោះទីទ័លក្រ ដាច់ស្បៀងជាស្ថាពរ ខូចខាត បាត់បង់ទ្រព្យសម្បត្តិ ផ្ទះសម្បែងប៉ះពាល់មុខរបរ ឬសុខភាព និងខូចខាតផលដំណាំ ។ល។ ត្រូវពិនិត្យលទ្ធភាពគិតទៅតាមចំនួនសមាជិកគ្រួសារ ផ្តល់ជំនួយម្តងគត់ ដោយគិតជាថវិកាមិនលើសពី ២០០ ០០០រៀល ក្នុងមួយគ្រួសារ ដូចជា អង្ករ ៣០គ.ក្រ អំបិល ៥គ.ក្រ មុងខ្នាតធំ ១ កន្ទេលនីឡុងខ្នាតធំ១ និងភួយ ១<br>• ប្រជាជនរងគ្រោះដែលទទួលនូវការខូចខាតបាត់បង់ទ្រព្យសម្បត្តិ ឬផលដំណាំតិចតួច ។ល។ ត្រូវពិនិត្យលទ្ធភាពគិតទៅតាមចំនួនសមាជិកគ្រួសារ ផ្តល់ជំនួយម្តងគត់ ដោយគិតជាថវិកាមិនលើសពី ១០០ ០០០រៀល ក្នុងមួយគ្រួសារ ដូចជា អង្ករ ២៥ គ.ក្រ អំបិល ៥ គ.ក្រ និងមុងខ្នាតធំ១ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | • សំណើរបស់ប្រធានមន្ទីរ ស.អ.យរាជធានី ខេត្ត យោងតាមតារាងគំរូឧបសម្ព័ន្ធ<br>• សេចក្តីសម្រេចរបស់ក្រសួង ស.អ.យ |
| យោបល់ | ផ្អែកតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បី |

| | |
|---|---|
| | ឆ្លើយតប និងអនុវត្តគោលនយោបាយរាជរដ្ឋាភិបាល នូវកម្មវិធីជួយសង្គ្រោះប្រជាជនដាច់ស្បៀង ទីទ័លក្រ រងគ្រោះដោយធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតុផ្សេងៗ ក្រសួង ស.អ.យ ចាំបាច់ត្រូវបន្តបង្កើន និងធានានូវការអន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច បានចំទិសដៅ ចំមុខសញ្ញាធានាបាននូវការទទួលខុសត្រូវខ្ពស់ មានតម្លាភាព ក្នុងការប្រើប្រាស់ថវិកាតាមគោលការណ៍ហិរញ្ញវត្ថុសាធារណៈក្នុងទិសដៅលើកស្ទួយកាលានុវត្តភាពការងារ ការកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជនក្រីក្រ ជួយដល់ប្រជាជនទន់ខ្សោយជាងគេនៅក្នុងសង្គម បង្កឱកាសឱ្យបានទទួលនូវការឧបត្ថម្ភគាំទ្រទាំងស្មារតី និងសម្ភារ ជំរុញការស្តារនីតិសម្បទា និងសមាហរណកម្មក្នុងសង្គមជាតិ ចូលរួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងទទួលផ្លែផ្កានៃអភិវឌ្ឍន៍ប្រកបដោយសមធម៌។ លើកកម្ពស់សេវាសង្គមកិច្ចឈានជាជំហានៗពីការផ្តល់ជំនួយសង្គ្រោះទៅជាការរៀបចំឱ្យមានប្រព័ន្ធសន្តិសុខសង្គម ការធានារ៉ាប់រងសង្គម ដើម្បីធានាសុខុមាលភាពសង្គមជូនប្រជាជន តាមលទ្ធភាពសេដ្ឋកិច្ចជាតិដោយចាត់ទុកជាយុទ្ធសាស្រ្តសំខាន់ នៃគោលការណ៍បែងចែកភោគ ផលដោយសមធម៌ |

# កម្មវិធីការពារជនផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍

| | |
|---|---|
| ឈ្មោះសេវា | កម្មវិធីការពារជនផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ |
| ក្រសួង/ស្ថាប័នផ្ដល់សេវា | ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន និងយុវនីតិសម្បទា<br>• អគ្គនាយកដ្ឋានបច្ចេកទេស<br>• នាយកដ្ឋានសុខុមាលភាពសង្គម<br>• ការិយាល័យសេវាការពារជនផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍<br>• អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ |
| គោលបំណង<br>នៃការផ្ដល់សេវា | • បង្ការប្រយុទ្ធ ទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ ជំងឺអេដស៍ និងការពារជនប្រឈមមុខ និងរងផលប៉ះពាល់ដោយមេរោគអេដស៍ ជំងឺអេដស៍ និងការពារជនប្រឈមមុខ និងរងផលប៉ះពាល់ដោយមេរោគអេដស៍ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• ជួយដល់កុមារកំព្រា និងកុមារងាយរងគ្រោះ កុមាររងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជំងឺអេដស៍ នៅតាមសហគមន៍ ឱ្យគេមានលំនឹងក្នុងជីវិត ដូចជាជួយរកសេវាព្យាបាល ជួយឱ្យកុមារបានចូលរៀន..។ |
| មូលដ្ឋានគតិយុត្ត | • អនុក្រឹត្យ លេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ឆ្នាំ២០០៦ ស្ដីពី របបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅមណ្ឌលរបស់រដ្ឋ<br>• ប្រកាសលេខ ៦៤៦ ស.អ.យ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៦ ស្ដីពី ការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• ប្រកាសលេខ ០១០ ស.អ.យ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្ដីពី ការចាត់តាំងក្រុមការងារ ដើម្បីអនុវត្តកម្មវិធីមូលនិធិសកលជុំទី៧ |
| អតិថិជនដែលមាន<br>សិទ្ធិទទួលសេវា | • សង្គមជាតិ និងគ្រួសារកុមាររងផលប៉ះពាល់ដោយមេរោគអេដស៍ និងជំងឺអេដស៍<br>• ទារកកំព្រា កុមារកំព្រា ទារក កុមារពិការធ្ងន់ធ្ងរ មានជំងឺរ៉ាំរ៉ៃ ផ្ទុកមេរោគអេដស៍ ឬមានជំងឺអេដស៍<br>• ជនពិការមានជំងឺអេដស៍ ជនពិការអនាថាមានជំងឺអេដស៍ |

| | |
|---|---|
| ស្តង់ដារសេវា | ទារក កុមារមានផ្ទុកមេរោគអេដស៍ ឬជំងឺអេដស៍ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល ត្រូវទទួលរបបឧបត្ថម្ភដូចខាងក្រោម :<br>• ទារកអាយុ ២ឆ្នាំចុះ ទទួលរបបថ្លៃទឹកដោះគោ ក្នុង១ខែ៦០ ០០០រៀល និងថ្លៃសំលៀកបំពាក់ សម្ភារដំណេក អនាម័យ និងព្យាបាល ១ដងក្នុង ១ឆ្នាំ ១២០ ០០០ រៀល ( ទទួលពេលដើមឆ្នាំ )<br>• កុមារអាយុលើសពី ២ឆ្នាំ ទទួលរបបឧបត្ថម្ភថ្លៃម្ហូបអាហារ ១ខែ៤៥ ០០០ រៀល ថ្លៃសំលៀកបំពាក់ សម្ភារសិក្សា កីឡា សម្ភារដំណេក ផ្ទះបាយ អនាម័យ និងព្យាបាល ១ដង ក្នុង១ឆ្នាំ ១២០ ០០០រៀល( ទទួលពេលដើមឆ្នាំ)<br>• ទារក កុមារទទួលរបបប៉ប៉នសុខភាពបន្ថែមក្នុង ១ខែ ២០ ០០០រៀល<br>• ទារក កុមារអាយុ ៥ឆ្នាំចុះ ទទួលមរណភាពឧបត្ថម្ភម្តងគត់ សម្រាប់រៀបចំ ពិធីបុណ្យសព ស្មើប្រាក់ម្ហូបអាហារ ៦ខែ ( ២៧០ ០០០ រៀល)<br>• កុមារអាយុលើសពី ៥ឆ្នាំឡើង ទទួលមរណភាពឧបត្ថម្ភម្តងគត់ សម្រាប់ រៀបចំពិធីបុណ្យសព ស្មើប្រាក់ម្ហូបអាហារ ១២ខែ ( ៥៤០ ០០០រៀល ) |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | • សំណើរបស់ប្រធានមជ្ឈមណ្ឌល ឬប្រធានមន្ទីរ ស.អ.យ រាជធានី ខេត្ត<br>• សេចក្តីសម្រេចរបស់ក្រសួង |
| យោបល់ | • ការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងគោលបំណងបង្ការ ទប់ស្កាត់ការរីករាលដាល មេរោគអេដស៍ ជំងឺអេដស៍ និងការពារជន ប្រឈមមុខ និងរងផលប៉ះពាល់ដោយមេរោគអេដស៍ ជំងឺអេដស៍ដែលស្ថិត ក្រោមសមត្ថកិច្ចរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• ការចាត់តាំងក្រុមការងារដើម្បីអនុវត្តកម្មវិធី ក្នុងគោលបំណង និងទិសដៅ ជួយដល់កុមារកំព្រា និងកុមារងាយរងគ្រោះ កុមាររងផលប៉ះពាល់ ដោយសារ មេរោគអេដស៍ និងជំងឺអេដស៍ នៅតាមសហគមន៍ ឱ្យគេមានលំនឹងក្នុង ជីវិត ដូចជាជួយរកសេវាព្យាបាល ជួយឱ្យកុមារបានចូលរៀន .... ។ល ។<br>• បង្កើនការយកចិត្តទុកដាក់ដល់ជនរងគ្រោះស្នាក់នៅក្នុងមណ្ឌលរដ្ឋ ក្នុង គោលបំណងជួយជនរងគ្រោះគ្រប់ប្រភេទ ព្រមទាំងគ្រួសារដែលមានផ្ទុក មេរោគអេដស៍ |

# ការបើកផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន  និងគ្រួសារអតីតយុទ្ធជន

| | |
|---|---|
| ឈ្មោះសេវា | ការបើកផ្តល់របបសន្តិសុខសង្គម ជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• អគ្គនាយកដ្ឋានបច្ចេកទេស<br>• បេឡាជាតិអតីតយុទ្ធជន "ប.ជ.អ."<br>• អាសយដ្ឋានលេខ ៧៨៨  មហាវិថីព្រះមុនីវង្ស  រាជធានីភ្នំពេញ |
| គោលបំណង<br>នៃការផ្តល់សេវា | • បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង  និងបើកផ្តល់របបសន្តិសុខសង្គម  ជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជនឱ្យបានឆាប់រហ័ស និងមានតម្លាភាព |
| មូលដ្ឋានគតិយុត្ត | • ក្រឹត្យច្បាប់លេខ ១០ ក្រ.ច ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ របស់ក្រុមប្រឹក្សារដ្ឋ  នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី  របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្ម ចំពោះនគរបាលប្រជាជនកម្ពុជា<br>• ព្រះរាជក្រមលេខ ០៧ នស/៩៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីរបបសោធននិវត្តន៍  និងសោធនបាត់បង់សមត្ថភាពការងារ  ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ<br>• ព្រះរាជក្រមលេខ នស/រកម/០៤០៦/០០៨ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៦ វិសោធនកម្មច្បាប់ស្តីពី  របបសោធននិវត្តន៍  និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ<br>• ព្រះរាជក្រឹត្យលេខ នស/រកត/០៧១០/៥៩៥ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ ស្តីពី របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន<br>• អនុក្រឹត្យលេខ ១១៥ អនក្របក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពី ការអនុវត្តរបបសោធននិវត្តន៍ និងបាត់បង់សមត្ថភាពការងារ<br>• អនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ ស្តីពី របបឧបត្ថម្ភចំពោះយោធិនពលីមរណៈ បង្កស្លាប់ បាត់ខ្លួន  និងជនពិការ<br>• អនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៧ ស្តីពី ការបន្ថែមបៀវត្ស  ជូនកងយោធពលខេមរភូមិន្ទ  កងកម្លាំងនគរបាលជាតិនិវត្តជន មន្ត្រីបាត់បង់សមត្ថភាព ពលកម្ម និងយុទ្ធជនពិការ<br>• អនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៨ ស្តីពី ការតម្លើងប្រាក់ឧបត្ថម្ភប្រចាំខែ ជូនប្រពន្ធ ឬ ប្តី និងកូនរបស់មន្ត្រីរាជការស៊ីវិល |

| | |
|---|---|
| | កងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ និវត្តជន មន្ត្រីបាត់បង់សមត្ថភាពពលកម្ម និងយុទ្ធជនពិការ<br>• អនុក្រឹត្យលេខ ៩៣ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៨ ស្តីពី ការបន្ថែមបៀវត្ស ជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ<br>• អនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៨ ស្តីពី ការផ្តល់ប្រាក់បំណាច់ជីវភាព ជូនមន្ត្រីរាជការស៊ីវិល កងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ និងនិវត្តជន មន្ត្រីបាត់បង់សមត្ថភាពពលកម្ម យុទ្ធជនពិការ ដែលជាមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន<br>• អនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៩ ស្តីពី ការផ្តល់ប្រាក់បំណាច់ជីវភាព ជូនមន្ត្រីរាជការស៊ីវិល កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យុទ្ធជនពិការ និង អតីតយុទ្ធជន<br>• អនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ ស្តីពី របបឧបត្ថម្ភគោលនយោបាយចំពោះមន្ត្រីនគរបាលពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងជនពិការ<br>• អនុក្រឹត្យលេខ ១១៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩ ស្តីពី ការបន្ថែមបៀវត្ស ជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ<br>• អនុក្រឹត្យលេខ ២០៧ អនក្រ.បក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ ស្តីពី ការផ្តល់ប្រាក់បំណាច់ជីវភាពជូនមន្ត្រីរាជការស៊ីវិល កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ ជនបាត់បង់សមត្ថភាពពលកម្ម ដែលជាអតីតយុទ្ធជន<br>• អនុក្រឹត្យលេខ ២០៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ ស្តីពី ការកែប្រែតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សរ៍មូលដ្ឋាន និងការបង្កើនបៀវត្សរ៍សុទ្ធសាធ របស់មន្ត្រីរាជការ<br>• អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១០ ស្តីពី ការកែសម្រួល ការអនុវត្តការបើកប្រាក់សោធន ចំពោះមន្ត្រីរាជការដែលជានិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារ ជនពិការ និងគ្រួសារជនពលី គ្រួសារជនមរណៈ ដែលទទួលមុខតំណែងជា |

| | |
|---|---|
| | អ្នកនយោបាយ<br>• អនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១០ ស្តីពី ការបង្កើតបេឡាជាតិ អតីតយុទ្ធជន<br>• អនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ស្តីពី ការកែសម្រួល ការកំណត់របបឧបត្ថម្ភ និងរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ជូនកងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិ ដែលចូលនិវត្តន៍ បាត់បង់សមត្ថភាពការងារ ពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ<br>• សេចក្តីសម្រេចលេខ ២០ សសរ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពី របបគោលនយោបាយចំពោះជនពលី ពិការ<br>• សេចក្តីសម្រេចលេខ ៥២ សសរ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពី ការកែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយធានារ៉ាប់រងសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល<br>• ប្រកាសអន្តរក្រសួងលេខ ១៨០ សហវ.ប្រក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៧ ស្តីពី ការកំណត់ និងកែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយប្រចាំខែ ជូនកូនរបស់គ្រួសារជនពលី និងមរណៈ<br>• ប្រកាសអន្តរក្រសួងលេខ ១២៩ ប្រកអន ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៧ ស្តីពី ការកំណត់អំពីបែបបទផ្ទេរប្រគល់ការគ្រប់គ្រង ចំពោះនិវត្តជន និងជនបាត់បង់សមត្ថភាពការងារ<br>• ប្រកាសអន្តរក្រសួងលេខ ១២៨ ប្រកអន ចុះថ្ងៃទី០៧ ខែវិច្ឆកា ឆ្នាំ២០០៧ ស្តីពី ការបង្កើតគណៈកម្មការវាយតម្លៃកំរិតថ្នាក់បាត់បង់សមត្ថភាពការងារ ចំពោះយោធិនទាំងពីរភេទ នៃកងយោធពលខេមរភូមិន្ទ<br>• ប្រកាសអន្តរក្រសួងលេខ ១៨៧៧ ប្រក. ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០ ស្តីពី ការកំណត់បែបបទផ្ទេរ ប្រគល់ការគ្រប់គ្រង និវត្តជន និងជនបាត់បង់សមត្ថភាពការងារ<br>• ប្រកាសលេខ ៦៧៨ ស.អ.យ. ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៥ ស្តីពី នីតិវិធីអនុវត្ត របបឧបត្ថម្ភគោលនយោបាយចំពោះ ជនពលី មរណៈ ជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារ<br>• ប្រកាសលេខ ១៩៣ ស.អ.យ. ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦ ស្តីពី នីតិវិធី |

| | |
|---|---|
| | កំណត់ប្រាក់ឧបត្ថម្ភមួយលើកដំបូងជូនជនពិការ<br>• ប្រកាសលេខ ៤៣០ ស.អ.យ. ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៦ ស្តីពី ប្រាក់ឧបត្ថម្ភគោលនយោបាយធានារ៉ាប់រងសង្គម សម្រាប់ជនពិការជាអតីតយុទ្ធជន<br>• សារាចរណែនាំអន្តរក្រសួងលេខ ០០២ ស.អ.យ. ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ មុខសញ្ញាអតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ<br>• សារាចរណែនាំអន្តរក្រសួងលេខ ០០១ សណអក ចុះថ្ងៃទី២៩ ខែមិនា ឆ្នាំ ២០០៧ ស្តីពី របបឧបត្ថម្ភចំពោះយោធិន ពលី មរណៈ បង្គស្លាប់ បាត់ខ្លួន និងពិការ<br>• សារាចរណែនាំអន្តរក្រសួងលេខ ០០១ សរណ.សអយ.សបហវ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៨ ស្តីពី ការកំណត់ប្រាក់ឧបត្ថម្ភប្រចាំខែជូនគ្រួសារជនមរណៈ<br>• សារាចរណែនាំអន្តរក្រសួងលេខ ០០១ សរណន ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពី របបឧបត្ថម្ភគោលនយោបាយចំពោះមន្ត្រីនគរបាលពលី មរណៈ បង្គស្លាប់ បាត់ខ្លួន និងពិការ<br>• សារាចរណែនាំលេខ ០០៣ ស.អ.យ. ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពី ការដំឡើងប្រាក់របប១៥ភាគរយ ជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាព ការងារ ជាអតីតយុទ្ធជន<br>• សារាចរណែនាំលេខ ០០៥ ស.អ.យ. ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៧ ស្តីពី ការអនុវត្តប្រកាសអន្តរក្រសួងលេខ ១៨០ សបហវ ប្រក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៧ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពី ការកំណត់កែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយ ប្រចាំខែជូនកូនជនពលី និងមរណៈ<br>• សេចក្តីណែនាំលេខ ០១១ ស.អ.យ.ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពី ការអនុវត្តសារាចរណែនាំអន្តរក្រសួងលេខ ០០១ សរណ. សអយ.សបហវ<br>• សារាចរណែនាំលេខ ០០៥ ស.អ.យ. ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០០៨ ស្តីពី ការតម្លើងប្រាក់ឧបត្ថម្ភប្រចាំខែជូនប្រពន្ធ ឬប្តី កូនជនពិការ ជនពលី ជនមរណៈ និវត្តជន និងជនបាត់បងសមត្ថភាពការងារជាអតីតយុទ្ធជន<br>• សារាចរណែនាំលេខ ០០៧ ស.អ.យ. ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០៨ ស្តីពី |

| | |
|---|---|
| | ការបន្ថែមប្រាក់២០ភាគរយ ជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ ជាអតីតយុទ្ធជន<br>• សារាចរណែនាំលេខ ០០៩ សអយ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៨ ស្តីពីការផ្តល់ប្រាក់បំណាច់ជីវភាព ជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ ជាអតីតយុទ្ធជន<br>• ប្រកាសលេខ ៨៤២ ស.អ.យ. ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងត្រួតពិនិត្យ ផ្ទៀងផ្ទាត់មុខសញ្ញាអតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ<br>• សារាចរណែនាំលេខ ០០៦ ស.អ.យ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបន្ថែមប្រាក់២០ភាគរយ ជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ<br>• សារាចរណែនាំលេខ ០០២ ស.អ.យ. ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ ស្តីពីការផ្តល់ប្រាក់បំណាច់ជីវភាពជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ ជាអតីតយុទ្ធជន<br>• សារាចរណែនាំលេខ ០០១ ស.អ.យ.ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ ស្តីពីការផ្តល់ប្រាក់បំណាច់ជីវភាព ជូនជនពិការ និវត្តជននិងជន បាត់បង់សមត្ថភាពការងារ ដែលជាអតីតយុទ្ធជន<br>• សារាចរណែនាំលេខ ០០៨ ស.អ.យ. ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១០ ស្តីពីការបង្កើនប្រាក់២០ភាគរយ ជូននិវត្តជន ជនបាត់បង់សមត្ថភាពការងារ និងជនពិការដែលជាអតីតយុទ្ធជន<br>• សារាចរណែនាំលេខ០១១ ស.អ.យ.ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ ស្តីពីការបើកប្រាក់សោធនចំពោះមន្ត្រីរាជការដែលជានិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារ ជនពិការ និងគ្រួសារជនពលី គ្រួសារជនមរណៈ ដែលទទួលមុខតំណែងជាអ្នកនយោបាយ<br>• សារាចរណែនាំលេខ ០១៤ ស.អ.យ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការពង្រឹងការងារបើកផ្តល់ប្រាក់ឧបត្ថម្ភជូនអតីតយុទ្ធជន<br>• សារាចរណែនាំលេខ ០១៥ ស.អ.យ. ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ស្តីពី វិធានការដោះស្រាយការទិញ បញ្ចាំ លក់របបសន្តិសុខសង្គមរបស់អតីត យុទ្ធជន និងអតីតមន្ត្រីរាជការ |

| | |
|---|---|
| | • សារាចរណែនាំលេខ ០១៧ ស.អ.យ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការកែសម្រួលការកំណត់របបឧបត្ថម្ភ១លើកដំបូង ជូនគ្រួសារជនពលី គ្រួសារជនមរណៈ និងជនពិការ ដែលជាអតីតយុទ្ធជន |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | អតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារអតីតយុទ្ធជនរួមមាន :<br>• ជនពលី<br>• ជនមរណៈ<br>• ជនពិការ<br>• និវត្តជន<br>• ជនបាត់បង់សមត្ថភាពការងារ និង<br>• គ្រួសាររបស់អតីតយុទ្ធជន |
| ស្តង់ដារសេវា | អតីតយុទ្ធជន ទទួលបានរបបសន្តិសុខសង្គមលើតាវកាលិក ដូចខាងក្រោម :<br>• ការចូលនិវត្តន៍<br>• ការបាត់បង់សមត្ថភាពការងារ<br>• ពលី<br>• មរណៈ<br>• ពិការភាព<br>• មាតុភាព<br>• អាពាហ៍ពិពាហ៍គ្រាដំបូង<br>• ជំងឺ<br>• គ្រួសាររបស់ជនទាំងនេះ និងរបបបន្ថែម ផ្សេងៗ ដូចមន្ត្រីរាជការដែលកំពុងបម្រើការងាររដ្ឋ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | ទទួលស្គាល់អតីតយុទ្ធជនថ្មី ដែលផ្ទេរពីក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័នពាក់ពន្ធ័<br>• លិខិតផ្ទេរអតីតយុទ្ធជនគ្រប់ប្រភេទ (០២ច្បាប់)<br>• ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសចេញពីជួរ (០២ច្បាប់)<br>• បញ្ជីរាយនាម (០២ច្បាប់)<br>• លិខិតទទួលស្គាល់ (០២ច្បាប់)<br>• វិញ្ញាបនបត្របញ្ជាក់កម្រិតបាត់បង់សមត្ថភាពការងារ (០២ច្បាប់)<br>• លិខិតឧទ្ទេសនាមផ្តត់ផ្តង់ហិរញ្ញវត្ថុ (០២ច្បាប់)<br>• ជីវៈប្រវត្តិសង្ខេប (០២ច្បាប់) |

| | |
|---|---|
| | • លិខិតចម្លងព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសចេញពីជួរ (០២ច្បាប់)<br>• លុបអតីតយុទ្ធជនគ្រប់ប្រភេទ<br>• សំណើរបស់មន្ទីរ ស.អ.យ. រាជធានី ខេត្ត (០២ច្បាប់)<br>• តារាងឧបសម្ព័ន្ធ (០២ច្បាប់)<br>• លិខិតទទួលស្គាល់ជនពលី ឬជនមរណៈ (០២ច្បាប់)<br>• ប្រវត្តិរូបសង្ខេប (០២ ច្បាប់)<br>• តារាងបញ្ជាក់ប្រាក់ឧបត្ថម្ភប្រចាំខែ (០២ច្បាប់)<br>• សេចក្តីចម្លងសំបុត្រមរណភាព (០២ច្បាប់)<br>• ប្រកាសទទួលស្គាល់ និងតារាងឧបសម្ព័ន្ធ របស់ក្រសួង (០២ច្បាប់)<br>• បញ្ចូលប្រពន្ធ ឬ ប្តី និងកូនរបស់ជនពិការ និវត្តជន និង ជនបាត់បង់សមត្ថភាពការងារ<br>• សំណើរបស់មន្ទីរ ស.អ.យ រាជធានី ខេត្ត (០២ច្បាប់)<br>• តារាងឧបសម្ព័ន្ធនៃបញ្ជីរាយនាមអតីតយុទ្ធជន និងគ្រួសារ (០២ច្បាប់)<br>• សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្រកំណើត (០២ច្បាប់)<br>• លិខិតបញ្ជាក់ការសិក្សា (០២ច្បាប់)<br>• ផ្ទេរអតីតយុទ្ធជនគ្រប់ប្រភេទពីរាជធានី ខេត្តមួយ ទៅរាជធានី ខេត្តមួយ<br>• សំណើរបស់មន្ទីរ ស.អ.យ រាជធានី ខេត្ត (០២ច្បាប់)<br>• តារាងឧបសម្ព័ន្ធ នៃបញ្ជីរាយនាមអតីតយុទ្ធជន (០២ច្បាប់)<br>• សៀវភៅបើកប្រាក់ និងសាលាកបត្រ (០២ច្បាប់)<br>• សំណុំលិខិតរបស់សាមីខ្លួន ច្បាប់ដើម<br>• ពាក្យស្នើសុំផ្ទេររបស់សាមីខ្លួន (០២ច្បាប់)<br>• បើកប្រាក់រំលឹក និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនអតីតយុទ្ធជន<br>• សំណើរបស់មន្ទីរ ស.អ.យ រាជធានី ខេត្ត (០២ច្បាប់)<br>• តារាងឧបសម្ព័ន្ធ នៃបញ្ជីរាយនាមរបស់អតីតយុទ្ធជន (២ច្បាប់)<br>• ប្រកាសទទួលស្គាល់ និងផ្តល់របបឧបត្ថម្ភ |
| យោបល់ | |

# សេវាគម្រោងសហប្រតិបត្តិការ
# លើវិស័យអធិការកិច្ចការថែទាំជំនួសចំពោះកុមារ

| | |
|---|---|
| ឈ្មោះសេវា | កិច្ចសហប្រតិបត្តិការ លើវិស័យអធិការកិច្ចការថែទាំជំនួសចំពោះកុមារ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• អគ្គនាយកដ្ឋានបច្ចេកទេស<br>• នាយកដ្ឋានសុខុមាលភាពកុមារ<br>• ការិយាល័យអធិការកិច្ចការថែទាំជំនួសចំពោះកុមារ<br>• អាសយដ្ឋាន : អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ |
| គោលបំណង<br>នៃការផ្តល់សេវា | • ដើម្បីជំរុញឱ្យមណ្ឌលកុមារកំព្រារបស់រដ្ឋ និង NGOs និងអង្គការ NGOs មួយចំនួន ដែលផ្តល់ការឧបត្ថម្ភដល់ការថែទាំកុមារនៅតាមសហគមន៍ យកចិត្តទុកដាក់ថែទាំកុមារកំព្រា និងកុមារងាយរងគ្រោះឱ្យរស់នៅសមរម្យ និងទទួលបាននូវសិទ្ធិមូលដ្ឋានទាំង ៤ របស់កុមារ |
| មូលដ្ឋានគតិយុត្ត | • អនុសញ្ញាអង្គការសហប្រជាជាតិស្តីពី សិទ្ធិកុមារដែលកម្ពុជាជាសមាជិក ប្រកាសដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២<br>• អនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះ ស្នាក់នៅក្នុងមណ្ឌលរបស់រដ្ឋ<br>• ប្រកាសលេខ ០៣៨ ស.អ.យ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៥ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្តីពី ការបង្កើតគណកម្មាធិការប្រឹក្សា ការថែទាំជំនួសចំពោះកុមារ<br>• ប្រកាសលេខ ២១៧ ស.អ.យ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៦ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្តីពី ការដាក់ឱ្យអនុវត្តគោលនយោបាយស្តីពី ការថែទាំជំនួសចំពោះកុមារ<br>• ប្រកាសលេខ ៦១៦ ស.អ.យ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្តីពី បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារក្នុងមណ្ឌល |

| | |
|---|---|
| | • ប្រកាសលេខ ១៩៨ ស.អ.យ ចុះថ្ងៃទី១១ ខែមិនា ឆ្នាំ២០០៨ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្តីពី បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍<br>• ប្រកាសលេខ ១៤៩ ស.អ.យ ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៧ ស្តីពី ការកែសម្រួលសមាសភាព និងភារកិច្ចរបស់គណកម្មាធិការប្រឹក្សាការថែទាំជំនួសចំពោះកុមារ |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | • កុមារកំព្រា កុមារមានទំនាស់ជាមួយច្បាប់ កុមាររស់នៅក្នុងគ្រួសារក្រីក្រ កុមារពិការ កុមារទទួលផលប៉ះពាល់ ឬផ្ទុកមេរោគអេដស៍ ឬមានជំងឺអេដស៍ កុមារទទួលផលប៉ះពាល់ដោយសារអំពើហឹង្សាក្នុងគ្រួសារ កុមារទទួលផលប៉ះពាល់ដោយសារធាតុញៀន និងអំពើអបាយមុខ កុមារអនាថាតាមចិញ្ចើមថ្នល់ កុមារត្រូវបានរំលោភបំពាន និងកុមារត្រូវបានកេងប្រវ័ញ្ចដែលមានអាយុក្រោម ១៨ឆ្នាំបានទទួលឱ្យស្នាក់នៅក្នុងមណ្ឌល រយៈពេលខ្លី និងវែង និងទទួលបានការស្នាក់នៅហូបចុកគ្រប់គ្រាន់ |
| ស្តង់ដារសេវា | កុមារដែលរស់នៅក្រោមការថែទាំនៅក្នុងមណ្ឌលកុមារកំព្រារបស់រដ្ឋ និងNGOs និងកុមារដែលរស់នៅតាមសហគមន៍ដែលឧបត្ថម្ភដោយNGOs ទទួលបាននូវការរស់នៅសមរម្យតាមស្តង់ដានៃបទដ្ឋានអប្បបរមា នៃការថែទាំជំនួសចំពោះកុមារទៅតាមៈ<br>• អនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែ តុលា ឆ្នាំ២០០៦<br>• ប្រកាសលេខ ២១៧ ស.អ.យ ចុះថ្ងៃទី២៦ ខែ មេសា ឆ្នាំ២០០៦<br>• ប្រកាសលេខ ៦១៦ ស.អ.យ ចុះថ្ងៃទី២២ ខែ វិច្ឆិកា ឆ្នាំ២០០៦<br>• ប្រកាសលេខ ១៩៨ ស.អ.យ ចុះថ្ងៃទី១១ ខែមិនា ឆ្នាំ២០០៨ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | ទម្រង់បញ្ចេញ បញ្ចូលកុមារ<br>• ទម្រង់ត្រួតពិនិត្យសម្រាប់មណ្ឌលថែទាំកុមារ និងការថែទាំតាមសហគមន៍<br>• ទម្រង់ប្រមូលទិន្នន័យកុមាររស់នៅក្នុងមណ្ឌល |
| យោបល់ | |

# សេវាលើគំរោងសហប្រតិបត្តិការលើវិស័យសុំកូនអន្តរប្រទេស

| | |
|---|---|
| ឈ្មោះសេវា | កិច្ចសហប្រតិបត្តិការលើវិស័យសុំកូនអន្តរប្រទេស |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• អគ្គនាយកដ្ឋានបច្ចេកទេស<br>• នាយកដ្ឋាន សុខុមាលភាពកុមារ<br>• ការិយាល័យសុំកូនចិញ្ចឹម<br>• អាសយដ្ឋាន : អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ |
| គោលបំណង<br>នៃការផ្តល់សេវា | • ការផ្តល់សេវាដល់កុមារ ដើម្បីឱ្យកុមារអាចទទួលបាននូវសិទ្ធ និងកាតព្វកិច្ចជាកូនស្របច្បាប់ក្នុងគ្រួសារជាអចិន្ត្រៃយ៍ |
| មូលដ្ឋានគតិយុត្ត | • អនុសញ្ញាស្តីពី សិទ្ធិកុមារដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជាបានសុំចូលជាភាគី នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២<br>• ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៣ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេស្តីពី ការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស<br>• ព្រះរាជក្រមលេខ នស/រកម/១២០៩/០២៤ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សុំកូនអន្តរប្រទេស<br>• ប្រកាសលេខ ៣០៨ សអយ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្តីពី ការបង្កើតអាជ្ញាធរកណ្តាល សុំកូនអន្តរប្រទេសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៃព្រះរាជាណាចក្រកម្ពុជា<br>• ប្រកាសលេខ ៣០៩ សអយ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្តីពី ការតែងតាំងសមាសភាពគណៈកម្មាធិការអាជ្ញាធរកណ្តាល សុំកូនអន្តរប្រទេសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៃព្រះរាជាណាចក្រកម្ពុជា<br>• ប្រកាសលេខ ៣១០ សអយ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្តីពី ការរៀបចំ និងការ |

| | |
|---|---|
| | ប្រព្រឹត្តទៅ នៃរដ្ឋបាលសុំកូនអន្តរប្រទេស<br>• ប្រកាសលេខ ៣១១ ស.អ.យ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្តីពី បែងចែកភារកិច្ចដល់មន្ត្រីរដ្ឋបាលសុំកូនអន្តរប្រទេស<br>• អនុក្រឹត្យលេខ ២៩ អនក្រ. បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០១ ស្តីពីការសុំទារក ឬកុមារកំព្រាយកទៅចិញ្ចឹមជាកូននៅបរទេស |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | • កុមារកំព្រាដែលមានអាយុក្រោម ០៨ឆ្នាំ គិតត្រឹមថ្ងៃទទួលពាក្យសុំ លើកលែងតែករណីកុមារត្រូវការនូវការថែទាំពិសេស ដែលអាចអនុញ្ញាតបានដល់កុមារអាយុក្រោម ១៨ឆ្នាំ។ ក្នុងករណីកុមារមានបងប្អូនបង្កើតច្រើននាក់ ហើយម្នាក់មានអាយុក្រោម ៨ឆ្នាំ អាចអនុញ្ញាតឱ្យសុំកុមារនោះរួមជាមួយនឹងបងប្អូនបង្កើតដែលមានអាយុក្រោម ១៨ឆ្នាំ។ ហើយរស់នៅក្នុងមណ្ឌលរដ្ឋ និងមណ្ឌលអង្គការក្រៅរដ្ឋាភិបាល |
| ស្តង់ដារសេវា | • កុមារដែលស្ថិតក្នុងករណីសុំកូនអន្តរប្រទេស ជាសុំកូនពេញលេញដែលត្រូវចម្រើនធំធាត់នៅក្នុងបរិយាកាសគ្រួសារ បរិយាកាសសុភមង្គល សេចក្តីស្រឡាញ់ និងការយោគយល់ ដើម្បីឱ្យមានការអភិវឌ្ឍពេញលេញ និងយ៉ាងសុខដុមនូវបុគ្គលិកលក្ខណៈរបស់ខ្លួន ហើយបង្កើតនូវទំនាក់ទំនងរវាងអ្នកសុំ និងកូនសុំជាអចិន្ត្រៃយ៍ដែលផ្តល់ដល់កុមារនូវឋានៈ សិទ្ធិ និងកាតព្វកិច្ចដូចជាកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមនោះ។ កុមារអាចអនុញ្ញាតសុំកូនបានក្រោយពីផ្តល់ការឧបត្ថម្ភគាំទ្រ ដើម្បីឱ្យកុមាររស់នៅក្នុងគ្រួសារកំណើត និងក្រោយពីបានធ្វើការពិចារណាអំពីសុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជាអស់លទ្ធភាព។ |
